# ក

# មាតិកា

## I. ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ


១២-០២-២០១៣-ព្រះរាជក្រឹត្យ នស/រកត/០២១៣/១៤៩ ស្តីពី ការតែងតាំងឯកឧត្តម **ង៉ាន ម៉ិនឡេង** ជាទីប្រឹក្សាក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និង អធិការកិច្ច មានឋានៈស្មើ អគ្គនាយក ១៩២១

១២-០២-២០១៣-ព្រះរាជក្រឹត្យ នស/រកត/០២១៣/១៥០ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះ អង្គភាពសម្ព័ន្ធមេត្រី ០១ រួមនឹងមន្ត្រីរាជការកងកម្លាំងប្រដាប់អាវុធ និង សប្បុរសជន ចំនួន ៩៥ រូប ១៩២២

១២-០២-២០១៣-ព្រះរាជក្រឹត្យ នស/រកត/០២១៣/១៥១ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា តាមលំដាប់ថ្នាក់ ចំពោះ មន្ត្រីរាជការ ចំនួន ០៤ រូប ១៩២៥

១២-០២-២០១៣-ព្រះរាជក្រឹត្យ នស/រកត/០២១៣/១៥២ ស្តីពី ការផ្លាស់ប្តូរក្របខ័ណ្ឌ លោក **ជា ម៉ូលី** ពីក្របខ័ណ្ឌមន្ត្រីក្រមការ ឋានន្តរសក្តិនាយក្រមការថ្នាក់លេខ ៥ ទៅក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល ឋានន្តរសក្តិអនុមន្ត្រី ថ្នាក់លេខ ១៤ របស់ក្រសួងអភិវឌ្ឍន៍ជនបទ ជាករណីពិសេស ១៩២៦

១២-០២-២០១៣-ព្រះរាជក្រឹត្យ នស/រកត/០២១៣/១៥៣ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស សហមេត្រី ថ្នាក់ មហាសេនា ចំពោះ ឧត្តមសេនីយ៍ត្រី **វូ ជៀនថាំង** (Brigadier General **Vu Chien Thang**) ប្រធានស្នងការការបរទេស កងទ័ពប្រជាជនវៀតណាម ១៩២៧

១២-០២-២០១៣-ព្រះរាជក្រឹត្យ នស/រកត/០២១៣/១៥៤ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា តាមលំដាប់ថ្នាក់ ចំពោះ លោកស្រី អស់លោក ជាថ្នាក់ដឹកនាំមន្ទីរ អង្គភាព ក្រុង ស្រុក ក្នុងខេត្តបាត់ដំបង ចំនួន ៩៤ រូប ១៩២៨

១២-០២-២០១៣-ព្រះរាជក្រឹត្យ នស/រកត/០២១៣/១៥៥ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ តាមលំដាប់ថ្នាក់ ចំពោះ សប្បុរសជន ចំនួន ០២ រូប ១៩៣០

១២-០២-២០១៣-ព្រះរាជក្រឹត្យ នស/រកត/០២១៣/១៥៦ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **លី សាងហ្យុគ** (LEE SANGHYUK) ជនជាតិកូរ៉េ សញ្ជាតិកូរ៉េ កើតនៅ ទីក្រុងសេអ៊ូល សាធារណរដ្ឋកូរ៉េ ១៩៣១

១២-០២-២០១៣-ព្រះរាជក្រឹត្យ នស/រកត/០២១៣/១៥៧ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **អាន់ យ៉ុងបេ** (AHN YONG BAE) ជនជាតិកូរ៉េ សញ្ជាតិកូរ៉េ កើតនៅ ខេត្តយ៉ុងសានង៉ាម សាធារណរដ្ឋកូរ៉េ ដោយប្តូរឈ្មោះជា **ជា សម្បត្តិ** (CHEA SAMBATH) ១៩៣២

១២-០២-២០១៣-ព្រះរាជក្រឹត្យ នស/រកត/០២១៣/១៥៨ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **លីន ជីនប៉ូ** (LIN CHIN-PO) ជនជាតិចិន សញ្ជាតិអាហ្វ្រិកខាងត្បូង កើតនៅ ខេត្តក្វាងទុង សាធារណរដ្ឋប្រជាមានិតចិន ១៩៣៣

១៣-០២-២០១៣-ព្រះរាជក្រឹត្យ នស/រកត/០២១៣/១៥៩ ស្តីពី ការតែងតាំងឯកឧត្តម **លឹម ស៊ីវេនីន** ជាទីប្រឹក្សាផ្ទាល់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា មានឋានៈស្មើ រដ្ឋមន្ត្រី បន្ថែមលើមុខងារបច្ចុប្បន្ន ដោយពុំទទួលប្រាក់បៀវត្សរ៍ ១៩៣៤

១៣-០២-២០១៣-ព្រះរាជក្រឹត្យ នស/រកត/០២១៣/១៦០ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស ជាតួបការ ចំពោះ លោកជំទាវ **ជុំ សាមីន តែប ជុំតិមា** ១៩៣៥

១៣-០២-២០១៣-ព្រះរាជក្រឹត្យ នស/រកត/០២១៣/១៦១ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះ មន្ត្រីរាជការ និង សប្បុរសជន ចំនួន ០៨ រូប ១៩៣៦

១៣-០២-២០១៣-ព្រះរាជក្រឹត្យ នស/រកត/០២១៣/១៦២ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះ មន្ត្រីរាជការ នាយទាហាន និង សប្បុរសជនជាតិ-អន្តរជាតិ ចំនួន ៦៥ រូប ១៩៣៧

១៣-០២-២០១៣-ព្រះរាជក្រឹត្យ នស/រកត/០២១៣/១៦៣ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះ មន្ត្រីរាជការ នៃក្រសួងកិច្ចការនារី ចំនួន ០៤ រូប ១៩៣៩

១៣-០២-២០១៣-ព្រះរាជក្រឹត្យ នស/រកត/០២១៣/១៦៤ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា តាមលំដាប់ថ្នាក់ ចំពោះ ថ្នាក់ដឹកនាំ និងមន្ត្រីរាជការ នៃខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី ចំនួន ០៨ រូប ១៩៤០

## II~រាជរដ្ឋាភិបាល

### ១~អនុក្រឹត្យ

១៨-០២-២០១៣-អនុក្រឹត្យលេខ ៦៦ អនក្រ.បក ស្តីពី ការរៀបចំ និង ការប្រព្រឹត្តទៅ របស់អគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីអភិវឌ្ឍយុវជន ១៩៤១

១៨.០២.២០១៣ - អនុក្រឹត្យលេខ ៦៧ អនក្រ.បក ស្តីពី ការកែសំរួលមាត្រា ១ និង មាត្រា ២ នៃអនុក្រឹត្យលេខ ១៩៧ អនក្រ.បក ចុះថ្ងៃទី ០២ ខែវិច្ឆិកា ឆ្នាំ ២០១២ ស្តីពី កាត់ដីទំហំសរុប ១.៩៧១,៨៧ ហិកតា ចេញពីគម្រប់ព្រៃឈើ ឆ្នាំ ២០០២ និង ធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ ដើម្បីធ្វើប្រទានកម្មជូនប្រជាពលរដ្ឋ ដែលបានកាន់កាប់ ប្រើប្រាស់ និង ដាំដុះជាក់ស្តែង នៅភូមិស្ទឹងឆាយជើង ភូមិស្ទឹងឆាយត្បូង ភូមិអូរតាហាយ ឃុំស្ទឹងឆាយ និង ភូមិសម្តេចតា ឃុំចំការហ្លួង ស្រុកកំពង់សីលា ខេត្តព្រះសីហនុ ១៩៤៨

២១.០២.២០១៣ - អនុក្រឹត្យលេខ ៦៨ អនក្រ.បក ស្តីពី ការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់.ក្រោមជាតិ ១៩៥១

២១.០២.២០១៣ - អនុក្រឹត្យលេខ ៦៩ អនក្រ.បក ស្តីពី ការកាត់ដីទំហំ ៦៥១,៩៤ ហិកតា នៅក្នុងស្រុកគីរីវង់ ខេត្តតាកែវ ចេញពីគម្របព្រៃឈើ ឆ្នាំ ២០០២ ដើម្បីធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្ម ជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និង រក្សាទុកមួយចំណែកជាដីសាធារណៈរបស់រដ្ឋ ១៩៥៨

០៤.១២.២០១២ - អនុក្រឹត្យលេខ **២៦៨៨** ដល់អនុក្រឹត្យលេខ **២៧០០** អនក្រ.តត ស្តីពី ការជូនមេដាយការងារ ១៩៦៤

០៤.១២.២០១២ - អនុក្រឹត្យលេខ ២៧០១ អនក្រ.តត ស្តីពី ការតែងតាំងមុខតំណែងនាយនគរបាលជាតិ ១៩៧៧

០៤.១២.២០១២ - អនុក្រឹត្យលេខ **២៧០២** ដល់អនុក្រឹត្យលេខ **២៧៣០** អនក្រ.តត ស្តីពី ការជូនមេដាយការងារ ១៩៧៨

## ២_សេចក្តីសម្រេច

២២.០២.២០១៣ - សេចក្តីសម្រេចលេខ ០៧ សសរ ស្តីពី ការតែងតាំងសមាសភាពគណៈកម្មាធិការជាតិជំរឿនកសិកម្ម នៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៣ ២០០៧

២២.០២.២០១៣ - សេចក្តីសម្រេចលេខ ០៨ សសរ ស្តីពី ការកំណត់យុទ្ធនាការ " ទេសចរម្នាក់ ដើមឈើមួយដើម " ២០០៩

## III_ការិយាល័យក្រសួង

## ១_ទីស្តីការគណៈរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង ក្រសួងព្រះបរមរាជវាំង

២៩.០១.២០១៣ - ប្រកាសរួមលេខ ១៣២ សហវ.ប្រក ស្តីពី ការផ្តល់សេវាសាធារណៈរបស់ ក្រសួងព្រះបរមរាជវាំង ២០១១

២៩-០១-២០១៣ - ប្រកាសរួមលេខ ១៣៣ សហវ.ប្រក ស្ដីពី ការផ្ដល់រង្វាន់លើកទឹកចិត្តជូន ក្រសួងព្រះបរមរាជវាំង និង ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ២០១៥

## ២. ទីស្ដីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
## និង
## រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល

២៩-០១-២០១៣ - ប្រកាសរួមលេខ ១៣៤ សហវ.ប្រក ស្ដីពី ការផ្ដល់សេវាសាធារណៈរបស់ រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល ២០១៩

២៩-០១-២០១៣ - ប្រកាសរួមលេខ ១៣៥ សហវ.ប្រក ស្ដីពី ការផ្ដល់រង្វាន់លើកទឹកចិត្តជូន រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល និង ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ២០៣១

# ព្រះរាជក្រឹត្យ

នស/រកត/០២១៣/១៤៩

យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សម្ពូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/០៦៩៩/០៥ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១.-** តែងតាំងឯកឧត្តម **ផាំង ប៊ុនឡេង** ជាទីប្រឹក្សាក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច មានឋានៈស្មើ អគ្គនាយក ។

**មាត្រា ២.-** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យ នេះ ។

**មាត្រា ៣.-** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣១៧. ១៣០៤. ១៤០

លេខៈ ១៥៧ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ១ ខែ មីនា ឆ្នាំ២០១៣
អគ្គលេខាធិការរង ទីស្តីការគណៈរដ្ឋមន្ត្រី

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០១៣

ជ័យ សុខា

# ព្រះរាជក្រឹត្យ

នស/រកត/០២១៣/១៥០

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រទានព្រះរាជទាន

ចំពោះ

អង្គភាពសម្ព័ន្ធមេត្រី ០១ រួមនឹងមន្ត្រីរាជការកងកម្លាំងប្រដាប់អាវុធ និងសប្បុរសជន ចំនួន ៩៥រូប ដែលមានស្នាដៃល្អ ក្នុងការរួមចំណែកបរិច្ចាគកម្លាំងកាយ-ចិត្ត សម្ភារៈ ថវិកា ឧបត្ថម្ភ ដល់កងពលតូចទ័ពពិសេសឆត្រយោង៩១១ កន្លងមក សម្រេចបានលទ្ធផលល្អប្រសើរ

នូវ

ក-គ្រឿងឥស្សរិយយសសេនាជ័យសិទ្ធ

-ក្រសួងអប់រំយុវជន និងកីឡា

ខ-គ្រឿងឥស្សរិយយស សម្តេចព្រះមហាក្សត្រីយានី ព្រះស៊ីសុវត្ថិមុនីវង្សកុសុមៈនារីរ័ត្ន ថ្នាក់ មហាសេរីវឌ្ឍន៍

១-ឯកឧត្តម ចាប ភក្តី
២-លោកជំទាវឧកញ៉ា ស៊ុយ សុផាន

គ-គ្រឿងឥស្សរិយយសសុវត្ថារា ថ្នាក់ មហាសេរីវឌ្ឍន៍

-ឯកឧត្តម ឧកញ៉ា តាំង គីមចុង

ឃ-គ្រឿងឥស្សរិយយសមុនីសារាភ័ណ្ឌ ថ្នាក់ មហាសេរីវឌ្ឍន៍

១-លោកជំទាវ ថែម សេរីរដ្ឋ
២-លោកជំទាវ ឆន ហ៊ីន
៣-លោកជំទាវ សៀម ឆេងហាន
៤-លោកស្រី ហាក់ ណៃ

ង-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេនា

-វរសេនីយ៍ទោ ម៉ៅ ចាន់រិទ្ធ ០១៧៤៤៦

ច-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ ធិបឌិន្ទ

១-ឯកឧត្តម យី យ៉េន
២-លោក ស៊ុយ សុធា
៣-លោក ស៊ុយ សុធី
៤-វរសេនីយ៍ទោ យ៉ឹម រដ្ឋា ០១០៣២២
៥-វរសេនីយ៍ទោ មាស សុវណ្ណ ០១៥១៧៨
៦-វរសេនីយ៍ទោ ឃួន អែត ០០៩៤៥០
៧-វរសេនីយ៍ទោ យ៉ឹម សុខា ០១២៣២៥
៨-វរសេនីយ៍ត្រី ផល សាមុត ០២៧០៣១
៩-វរសេនីយ៍ត្រី ចាប សុភ័ណ្ឌ ០៤០៧២២

**ឃ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ សេនា :**

១-វរសេនីយ៍ត្រី ហុង ចាន់ហេង ០២៤៤៦០
២-វរសេនីយ៍ត្រី លុយ ដារ៉ា ០១២៣៤៦
៣-វរសេនីយ៍ទោ ពេទ្យ ម៉ាលី ០១០៣២៤
៤-អនុសេនីយ៍ឯក សាន ពៅ ០៤០៧៤៥
៥-វរសេនីយ៍ត្រី អៀង តៃឡា ០១៩៣៨១
៦-វរសេនីយ៍ត្រី ឃី ថុន ០១៩៣៧២
៧-អនុសេនីយ៍ឯក ស្រិល វៀន ០១៧៤៥៤
៨-វរសេនីយ៍ត្រី ប៉ាន សេនចាន់ ០១៩៣៩៧
៩-អនុសេនីយ៍ឯក ឆាយ នី ០២៦៩៧១
១០-អនុសេនីយ៍ឯក ឈូក វណ្ណា ០៤៩៧៥៧
១១-អនុសេនីយ៍ឯក ថោង ម៉ាល័យ ០៤០៧២៥
១២-អនុសេនីយ៍ឯក ហាន សុខហាន ០២៧៥១១
១៣-អនុសេនីយ៍ឯក សុខ ចំរើន ០១៩៣៧៩
១៤-វរសេនីយ៍ត្រី ស៊ឹម អ៊ី ០២៤៤៧៣
១៥-វរសេនីយ៍ត្រី មាស ណុបគុណ ០១៩៣៩៩
១៦-អនុសេនីយ៍ឯក អ៊ុង ចំរើន ០៥៩១៧១
១៧-អនុសេនីយ៍ឯក កង សុខន ០៤០៦៧៧
១៨-វរសេនីយ៍ទោ អ៊ី អឿន ០១៩៣៨៦
១៩-វរសេនីយ៍ទោ ជុន សាមឿន ០២៤៤៦៧
២០-វរសេនីយ៍ត្រី គីម ឃីម ០១០៣២៨
២១-វរសេនីយ៍ត្រី ឈឿន រតនៈ ០១៩៣៧៤
២២-អនុសេនីយ៍ទោ គង់ គុណា ០៤៩៨៦៦
២៣-អនុសេនីយ៍ឯក ជេត វណ្ណី ០៤០៧១៦
២៤-វរសេនីយ៍ទោ សាំង ម៉េង ០០៩៤៤៦
២៥-អនុសេនីយ៍ឯក ប៉ុល សារឿន ០២៦៩៩៦

**ង-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ អស្សឫទ្ធិ :**

១-វរសេនីយ៍ទោ សួន ដន ០១២៣២៦
២-វរសេនីយ៍ត្រី កែវ សំណាង ០១៥១៧៩
៣-អនុសេនីយ៍ឯក ឡេង វណ្ណនី ០១៩៣៧៨
៤-អនុសេនីយ៍ទោ វ៉ាញ់ អ៊ុល ១៦៧៦៤២
៥-អនុសេនីយ៍ទោ លីវ វ៉ាត់ ១៦៧៦៤៣
៦-អនុសេនីយ៍ទោ លីវ ថ្មី ១៦៧៦៤៤
៧-អនុសេនីយ៍ទោ ថែម សេរីរក្ស ០៣៣២១៧
៨-អនុសេនីយ៍ត្រី អ៊ុក សាកុល ១៦៧៦៤៥
៩-អនុសេនីយ៍ទោ សុក ប៊ុនធឿន ០៤០៦២៣
១០-អនុសេនីយ៍ឯក គង់ យូរ៉ា ០២៤៤៥៩
១១-អនុសេនីយ៍ឯក វ៉ុន ស៊ីថាត ០៥៨២២០
១២-អនុសេនីយ៍ឯក សង់ លីហុក ០២៦៩៩៤
១៣-វរសេនីយ៍ត្រី ឈឹម ផា ០១៩៣៧៧
១៤-អនុសេនីយ៍ឯក ហង្ស ស៊ីន ០២៤៤៧៤
១៥-អនុសេនីយ៍ឯក ញឹម សុណ្ណ ០៤៩៧៦៤
១៦-អនុសេនីយ៍ឯក ឡុង រត្ន័មុន្នី ០១៧៤៥៩
១៧-វរសេនីយ៍ត្រី ឈឹម ប៊ុនធឿន ០២១២៦៩
១៨-អនុសេនីយ៍ឯក ធូ គឹមសាន្ត ០២៦៩៩៧
១៩-អនុសេនីយ៍ឯក សោម លាប ០២៦៩៨៤
២០-អនុសេនីយ៍ឯក មួន ង៉ា ០៦៨២៦៣
២១-អនុសេនីយ៍ឯក ទេស សុភាព ០២៦៩៦៧
២២-ពលបាលទោ ឌី សាវ៉ាន ២០៧៨៦៧
២៣-អនុសេនីយ៍ឯក យ៉ត ផល្លា ០៣៣២១៨
២៤-វរសេនីយ៍ត្រី យិន តារា ០១៩៣៨៣
២៥-អនុសេនីយ៍ឯក សាន សុទ្ធី ០២០៨១២
២៦-អនុសេនីយ៍ទោ សួន គិត ០៤០៦២២
២៧-វរសេនីយ៍ត្រី នួន គង្គា ០៣១៦២៤
២៨-អនុសេនីយ៍ទោ តុន សារ៉ុន ០៤០៦៥៣
២៩-អនុសេនីយ៍ត្រី ពុំ រត្ន័ ០២៧៥៣៤
៣០-អនុសេនីយ៍ទោ នង អេង ០២៧៥៣៥
៣១-វរសេនីយ៍ត្រី ស៊ឹម សំអុល ០១៩៣៨៧
៣២-អនុសេនីយ៍ឯក អ៊ី សំអែ ០១៩៣៨៥
៣៣-អនុសេនីយ៍ឯក លា ធី ០៤៩៨៥៤
៣៤-វរសេនីយ៍ត្រី ម៉ៅ សាវ៉ាវុធ ០១៧៤៣៧
៣៥-អនុសេនីយ៍ឯក ឃុត សុឃាង ០១៩៣៧៥
៣៦-អនុសេនីយ៍ទោ ណង សារ៉ន ០៤០៦៨៤
៣៧-អនុសេនីយ៍ឯក ហ៊ិត សុខា ០២៧០០២
៣៨-វរសេនីយ៍ត្រី តុង ស្រេង ០១៩៤០០
៣៩-វរសេនីយ៍ត្រី ឡូញ ប៊ុនឈឿន ០៣៩៨៣០
៤០-អនុសេនីយ៍ឯក ស៊ឹម ភារិន ០២៧០១៩
៤១-អនុសេនីយ៍ឯក សេង ឡៃហ៊ន់ ០២៧០២២
៤២-អនុសេនីយ៍ឯក ចាប់ ផន ០១៧៤៧៥
៤៣-វរសេនីយ៍ត្រី ហ៊ុយ សាត ០២៧៥២៤
៤៤-វរសេនីយ៍ត្រី អ៊ុក សំណាង ០១៧៤៧០
៤៥-វរសេនីយ៍ត្រី សាវ៉ាយ សុខា ០២៧០២៣
៤៦-អនុសេនីយ៍ឯក ស៊ុន សាយ័ណ្ណ ០១៧៤៦៩

| | | | | | | |
|---|---|---|---|---|---|---|
| ៤៧-អនុសេនីយ៍ទោប៉ោ | សុផល | ០៥០០១៣ | | ៥១-អនុសេនីយ៍ឯក ស្រេង សួរ្យ | | ០២៧៥៣៧ |
| ៤៨-អនុសេនីយ៍ឯក យូ | ថាត | ០៥០០១២ | | ៥២-អនុសេនីយ៍ឯក សំ | វណ្ណា | ០៣៩៨២០ |
| ៤៩-អនុសេនីយ៍ឯក ជា | ឡំ | ០២៧៥៣២ | | ៥៣-វរសេនីយ៍ត្រី ជា | សុភាព | ០២៧០២៤ |
| ៥០-អនុសេនីយ៍ឯក ឡឹក | យ៉ាន់ | ០២៦៩៩៩ | | | | |

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

*ពសស.១៣០២.១៩១*

លេខ: ១៧៧ ច.ល

**ដើម្បីចម្លងចែក**

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០១៣*

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ២០១៣

**អគ្គលេខាធិការរងទីស្តីការគណៈរដ្ឋមន្ត្រី**

**ស៊យ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០២១៣/១៥១

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ចំពោះ

មន្ត្រីរាជការ ចំនួន ០៤រូប ដែលមានស្នាដៃល្អ និងគុណបំណាច់ ក្នុងការបំពេញភារកិច្ច
ជួយអភិវឌ្ឍន៍មូលដ្ឋាន ក្នុងស្រុកល្វាឯម ខេត្តកណ្តាល

នូវ

ក- គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេរីវឌ្ឍន៍ :

ឯកឧត្តម ស៊ិន ច័ណ្ឌី

ខ- គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេនា :

១- លោក អៀង ណារិន

២- លោក ញ៉ែប សែ

គ- គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ អស្សឫទ្ធិ :

លោក ច័ន្ទ សម្បត្តិ

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣៩៧.១៣០៥.១៥៥

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០១៣

លេខៈ ១៦៧ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែកុម្ភៈ ឆ្នាំ២០១៣
អគ្គលេខាធិការរងទី១រាជរដ្ឋាភិបាល
សយ សុខា

# ព្រះរាជក្រឹត្យ

នស/រកត/០២១៣/១៥៤

យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រត្នត្តយាធិបតី ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១២ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងអភិវឌ្ឍន៍ជនបទ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ផ្លាស់ប្តូរក្របខ័ណ្ឌ លោក **ជា ប៊ុលី** ពីក្របខ័ណ្ឌមន្ត្រីក្រមការ ឋានន្តរសក្តិនាយក្រមការថ្នាក់លេខ៥ ទៅក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល ឋានន្តរសក្តិអនុមន្ត្រី ថ្នាក់លេខ ១៤ របស់ក្រសួងអភិវឌ្ឍន៍ជនបទ ជាករណីពិសេស ។

**មាត្រា ២ :** បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៣ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៤ :** ព្រះរាជក្រឹត្យនេះចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ចម្លងចេញពីច្បាប់ដើម
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី១ ខែ កុម្ភៈ ឆ្នាំ២០១៣
អគ្គលេខាធិការរាជរដ្ឋាភិបាល
សុយ សុខា

៣៣៤.០៣០៤.១៥៣

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០១៣

# ព្រះរាជក្រឹត្យ

នស/រកត/០២១៣/១៥៣

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតក្ខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា
សិរីវិបុលា ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

នូវ

គ្រឿងឥស្សរិយយស សហមេត្រី ថ្នាក់ មហាសេនា

ចំពោះ

ឧត្តមសេនីយ៍ត្រី វូ ជៀនថាំង ( Brigadier General **Vu Chien Thang** )
ប្រធានស្នងការការបរទេស កងទ័ពប្រជាជនវៀតណាម
ដែលមានស្នាដៃល្អក្នុងកិច្ចសហប្រតិបត្តិការ ជាមួយកងយោធពលខេមរភូមិន្ទ
ព្រមទាំងបានខិតខំបណ្តុះបណ្តាលជំនាញដល់នាយទាហាន នាយទាហានរង កងយោធពលខេមរភូមិន្ទ

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ពរល.១៣០២.១៥៤

ធ្វើនៅព្រះបរមរាជវាំង,ថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ២០១៣

លេខៈ១៧៣ ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ២០១៣
អគ្គលេខាធិការរងទីស្តីការរដ្ឋាភិបាល

**ស៊យ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០២១៣/១៥៤

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

**ចំពោះ**

លោកស្រី អស់លោកជាថ្នាក់ដឹកនាំមន្ទីរ អង្គភាព ក្រុង ស្រុកក្នុងខេត្តបាត់ដំបង បានខិតខំយកអស់កម្លាំងកាយ ចិត្ត បំពេញភារកិច្ច ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ រួមចំណែកក្នុងការអភិវឌ្ឍលើគ្រប់វិស័យក្នុងខេត្តអោយមានការរីកចម្រើនគួរជាទីមោទនៈ

**នូវ**

**ក-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេរីវឌ្ឍន៍ :**

១- លោក ឆាយ យូប
២- លោក គុយ សុខ
៣- លោក អ៊ូ ដារី

**ខ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេនា :**

១- លោក ជី ឈៀង
២- លោក ត្រូ ចំរើន
៣- លោក សួន ប៊ុនធឿន
៤- លោក អ៊ុចអ៊ុំ ភនីស្សាវ៉ា
៥- លោក ឡុង ផលគុណ
៦- លោក អៀ វ៉ាន់នី
៧- លោកស្រី អោ អៀង
៨- លោក ឥម គេង
៩- លោក ជួប សារុន
១០- លោក ជួង សុភា
១១- លោក លី ជូបៀង
១២- លោក ទីវ វ៉ាឌុឡ
១៣- លោក ព្រីង បញ្ញាឫទ្ធិ
១៤- លោក ព្រៅ ខេមរិទ្ធ
១៥- លោក សើ សាម៉េត
១៦- លោក មៀច សុមន៍
១៧- លោក អ៊ុង ប៊ុនជ័យ
១៨- លោក សួស សុផាត
១៩- លោក មូល ធន
២០- លោក នុត ប៊ុណ្ណា
២១- លោក សម សំអាត
២២- លោក នាង ច័ន្ទថាវ៉ា
២៣- លោក រឿន វ៉ាត
២៤- លោក ចែត្រ សិថា
២៥- លោក ឃឹម ទិព្វមុនី
២៦- លោក ហម សំខាន់
២៧- លោក យូន ស៊ីណាត
២៨- លោក ទឹម ជូនេត្រ
២៩- លោក ពុធ ទ្រី
៣០- លោក ធឿង ស៊ិន
៣១- លោក លឹម ហឿង
៣២- លោក សាឯម សេដ្ឋា

**គ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ ធិបឌិន្ទ :**

១- លោក អ៊ុកវង្ស ឡុងវ
២- លោកស្រី ថន ចាន់ថៃ
៣- លោក ជា សម្បត្តិ
១១- លោក ឆាយ សារី
១២- លោក ភោគ សាវង្ស
១៣- លោក ឌី ពៀច

៤- លោក គុប ប៊ុនធាន
៥- លោក ធឿន ហេង
៦- លោក គោគ កត្យា
៧- លោក ថង មុនី
៨- លោក អ៊ិន ប៊ុនម៉ាត់
៩- លោក រិត សាបឿន
១០- លោក សៀងឯម សត្យា
១៤- លោក សុត សុផុន
១៥- លោក ប៊ួយ សុខលី
១៦- លោកស្រី ទី ម៉ារ៉ាឌី
១៧- លោកស្រី ឯម សោភ័ណរតនា
១៨- លោកស្រី ម៉ម យ៉ាន
១៩- លោក ម៉ុក សារិទណ្ណា
២០- លោក ឈឹម សំណាង

ឃ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ សេនា :

១- លោក ថងឈិន សុភា
២- លោក ឆេង ជីវ៉ាត់
៣- លោក ណាត ចាន់រ៉េត
៤- លោក ជូ សាន
៥- លោក ឈឹម សាបុន
៦- លោក ខន ថវៈ
៧- លោកស្រី អៀង សិរី
៨- កញ្ញា រស់ ពៅធីតា
៩- លោក ឈឿត សុទ្ធា
១០- លោក ហុង ឆេត
១១- លោកស្រី អេន វណ្ណានី
១២- លោកស្រី សារ៉េង សុផានី
១៣- លោកស្រី កៅ ឈួនណារ៉ា
១៤- លោក ឯម ពិជ័យរតនៈ
១៥- លោក ធិត ទារ៉ា
១៦- លោក ល្អង ខន
១៧- លោកស្រី ចក់ ចរិយា
១៨- លោកស្រី ចន្ទ សុភា
១៩- លោក វ៉ាន់ ចាន់តុលា
២០- លោក អេ សុភា
២១- លោក សម សំអុន
២២- លោកស្រី ញ៉ែម ចាន់ថន
២៣- លោកស្រី គេង ចាន់ថុល
២៤- លោក សោម មុនី

ង-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ អស្សឫទ្ធិ :

១- លោក ជា សំហុន
២- លោកស្រី កែវ ដាណា
៣- លោក ប៉ោក រ៉ា
៤- លោកស្រី ណុប សុធី
៥- លោក ព្រុំ ជូកម្ព
៦- លោក គេង ចាន់ភរម្យ
៧- លោកស្រី ពៅ អមរា
៨- លោក រិត សុធាវ
៩- កញ្ញា តាត ម៉ាឡែន
១០- លោក រ៉ាត ច័ន្ទសិរី
១១- លោកស្រី ស្អូស សុចារី
១២- លោកស្រី ញឹក អ៊ិនសុភាវ
១៣- លោកស្រី ឈួន សំបូរ
១៤- លោក អ៊ឹម មិត្ត
១៥- លោក ឯម សិរីវឌ្ឍនា

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ពរស: ១៣០៤.៥៥

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០១៣

លេខ: ១៧៦ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ១ ខែ កុម្ភៈ ឆ្នាំ២០១៣
អគ្គលេខាធិការរង ទីស្ដីការរដ្ឋាភិបាល
ស៊យ សុខា

# ព្រះរាជក្រឹត្យ

នស/រកត/០២១៣/១៥៥

យើង

ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្ដម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ចំពោះ

សប្បុរសជន ចំនួន ០២រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួន
ជួយកសាងសមិទ្ធផលនានា ក្នុងវិស័យព្រះពុទ្ធសាសនា នៅក្នុងខេត្តស្វាយរៀង

នូវ

ក- គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេរីវឌ្ឍន៍ :
ឧកញ៉ា សៅ សុចណ្ឌី

ខ- គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា :
លោកជំទាវ អ៊ុំ ផន ប្រាក់ ណាក់

ព្រះហស្ដលេខា និងព្រះរាជលញ្ឆករ
នរោត្ដម សីហមុនី

ពរល.១៣០៤.១៥៥

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០១៣

លេខ:១៧៤ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ២០១៣
អគ្គលេខាធិការរងទី១ រាជរដ្ឋាភិបាល

ស៊ុយ សុខា

# ព្រះរាជក្រឹត្យ

នស/រកត/០២១៣/១៥៦

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សម្ពហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១** : ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **លី សាងហ្យុក** (LEE SANGHYUK) ជនជាតិកូរ៉េ សញ្ជាតិកូរ៉េ កើតថ្ងៃទី២១ ខែកក្កដា ឆ្នាំ១៩៦៥ នៅទីក្រុងសេអ៊ូល សាធារណរដ្ឋកូរ៉េ។

**មាត្រា ២** : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឲ្យបានសម្រេច នូវព្រះរាជក្រឹត្យនេះ។

**មាត្រា ៣** : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខា តទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

លេខៈ ១៥៣ ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ២០១៣
**អគ្គលេខាធិការរងទីស្តីការរាជរដ្ឋាភិបាល**
**ស៊យ សុខា**

គ.ស.ល. ១៣០៤. ១៥៧

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០១៣

# ព្រះរាជក្រឹត្យ

នស/រកត/០២១៣/១៥៧

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១** : ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **អាន់ យ៉ុងបេ** (AHN YONG BAE) ជនជាតិកូរ៉េ សញ្ជាតិកូរ៉េ កើតថ្ងៃទី០៦ ខែកក្កដា ឆ្នាំ១៩៥៦ នៅខេត្តយ៉ុងសានដាម សាធារណរដ្ឋកូរ៉េ ដោយប្តូរឈ្មោះជា **ជា សម្បត្តិ** (CHEA SAMBATH)។

**មាត្រា ២** : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឲ្យបានសម្រេច នូវព្រះរាជក្រឹត្យនេះ។

**មាត្រា ៣** : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខា តទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ពរល. ១៣០៤. ១៥៧

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០១៣

លេខ: ១៥៥ ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ២០១៣
**អគ្គលេខាធិការរងទីស្តីការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០២១៣/១៥៧

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **លីន ជីនប៉ូ** (LIN CHIN-PO) ជនជាតិចិន សញ្ជាតិអាហ្វ្រិកខាងត្បូង កើតថ្ងៃទី០១ ខែតុលា ឆ្នាំ១៩៦០ នៅខេត្តក្វាងទុង សាធារណរដ្ឋប្រជាមានិតចិន។

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឲ្យបានសម្រេច នូវព្រះរាជក្រឹត្យនេះ។

**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខា តទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ពរជ.១៣០៤.១៥៩

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០១៣

លេខៈ១៥៤ ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ២០១៣
**អគ្គលេខាធិការរងទីស្តីការគណៈរដ្ឋាភិបាល**

**ជ័យ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០២១៣/១៥៩

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១** : តែងតាំងឯកឧត្តម **លឹម ស៊ីវដេនីន** ជាទីប្រឹក្សាផ្ទាល់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា មានឋានៈស្មើ **រដ្ឋមន្ត្រី** បន្ថែមលើមុខងារបច្ចុប្បន្ន ដោយពុំទទួលប្រាក់បៀវត្សរ៍។

**មាត្រា ២** : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣** : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៧៤៥.១៣០២.១៦០

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ២០១៣*

លេខ:១៥៦ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១៣
អគ្គលេខាធិការ [illegible] រដ្ឋាភិបាល
[illegible] សុខា

# ព្រះរាជក្រឹត្យ

នស/រកត/០២១៣/១៦០

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា**
**សិរីវិបុលា ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

ប្រោសព្រះរាជទាន

នូវ

គ្រឿងឥស្សរិយយស ជាតូបការ

ចំពោះ

**លោកជំទាវ ជុំ សាមីន តែប ជុតិមា**

ដែលមានគុណបំណាច់យ៉ាងធំធេង និងមានស្នាដៃល្អ ក្នុងការចូលរួមចំណែក
កសាង និងអភិវឌ្ឍន៍ប្រទេសជាតិ

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣១៩.១៣០២.១៦១

លេខៈ១៦៣ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០១៣
អគ្គលេខាធិការ[illegible]រាជរដ្ឋាភិបាល
[illegible] សុខា

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ ២០១៣

# ព្រះរាជក្រឹត្យ

នស/រកត/០២១៣/១៦១

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

ប្រោសព្រះរាជទាន

ចំពោះ

មន្ត្រីរាជការ និង សប្បុរសជន ចំនួន ០៨រូប ដែលបានបរិច្ចាគកម្លាំងកាយ-ចិត្ត និងធនធាន ជួយកសាង អាគារសិក្សា ៥ខ្នង មាន២៥បន្ទប់ និងសមិទ្ធផលនានា ជាច្រើនទៀត នៅវត្តសង្កែស្ពួលកោះកែវរង្សី ឃុំស្ពួល ស្រុកក្រឡាញ់ ខេត្តសៀមរាប

នូវ

**ក-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេនា**

១- ឯកឧត្តមបណ្ឌិត លី ស៊ីណា
២- ឯកឧត្តម គុជ លីណា
៣- ឯកឧត្តម ឆា គីមសុខ
៤- លោក ឆា ស៊ីវត្ថា

**ខ-គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា**

១- លោក ហេង សុខអេង
២- លោក ច័ន្ទ សុខុមចិត្តា
៣- លោក នួន គ្រឹះស្នា
៤- លោក មឿង សុនិត្យា

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៧១៨-១៣០៤-១៦២

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៣ ខែកុម្ភៈ ឆ្នាំ២០១៣

លេខ: ១៥៩ ច.ល
សម្រាប់ចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែកុម្ភៈ ឆ្នាំ២០១៣
អគ្គលេខាធិការរងទី២ទីស្តីការគណៈរដ្ឋមន្ត្រី
ទីស្តីការគណៈរដ្ឋមន្ត្រី
ជ័យ សុខា

# ព្រះរាជក្រឹត្យ

នស/រកត/០២១៣/១៦៧

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានតួមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

## ប្រោសព្រះរាជទាន

ចំពោះ

មន្ត្រីរាជការ នាយទាហាន និង សប្បុរសជនជាតិ-អន្តរជាតិ ចំនួន ៦៥រូប ដែលមានស្នាដៃល្អក្នុងការបំពេញភារកិច្ច បម្រើជាតិមាតុភូមិ និងបានបរិច្ចាគថវិកា និងសម្ភារៈ ក្នុងការសាងសង់មណ្ឌលសុខភាពមរតកតេជោ និងសមិទ្ធផលនានាជាច្រើនទៀត នៅកងពលតូចលេខ៧០ កន្លងមកសម្រេចបានលទ្ធផលល្អប្រសើរ

នូវ

**ក-គ្រឿងឥស្សរិយយស ជាតូបការ**

- ឯកឧត្តម **យឹម យាន**

**ខ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេរីវឌ្ឍន៍**

១- ឯកឧត្តម **ឧូន សំណាង**
២- ឯកឧត្តម **ស្លាត សុភាព**
៣- ឧត្តមសេនីយ៍ត្រី **ជា ឧូន**
៤- លោកជំទាវ **សឿង សុភី**
៥- វរសេនីយ៍ឯក **ឧូន សាម**
៦- វរសេនីយ៍ឯក **អ៊ុំ វិសាល**
៧- វរសេនីយ៍ឯក **ឡេង សៀម**
៨- វរសេនីយ៍ឯក **អ៊ាត ប៊ុនធឿន**
៩- វរសេនីយ៍ទោ **ញ៉ឹក សេង**
១០- វរសេនីយ៍ត្រី **អៀង យាង**
១១- វរសេនីយ៍ត្រី **សៀម សំបូរ**
១២- វរសេនីយ៍ត្រី **សម្បត្តិ មុន្នីរ័ត្ន**
១៣- លោក **ញ៉ឹក អៀកឧូន**
១៤- លោក **រុន ពណ្ណារិទ្ធ**
១៥- ឧត្តមសេនីយ៍ត្រី **ខិន សាមឿន**
១៦- លោក **ម៉ក់ សុគ័ន្ធា**

**គ-គ្រឿងឥស្សរិយយស សុវត្ថារា ថ្នាក់ មហាសេរីវឌ្ឍន៍**

១- ឯកឧត្តម **លឹម វីរក្ស**
២- ឯកឧត្តម **មន់ សម្បត្តិ**
៣- វរសេនីយ៍ឯក **ឈឹម លីន អត្តលេខ ០០៣៤៧៧**
៤- វរសេនីយ៍ទោ **អ៊ុងប៊ុនចិន អត្តលេខ ០២៤២៧៣**
៥- លោក **ជាប សារឿន**
៦- លោក **ថោង ណារ៉េត**
៧- លោក **ផូ យាន**
៨- លោក **វណ្ណ វណ្ណា**
៩- លោក **លី ឧូន**
១០- លោក **លឹម ជី**

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

**ឃ-គ្រឿងឥស្សរិយយស សហមេត្រី ថ្នាក់ មហាសេរីវឌ្ឍន៍**

១- ឧត្តមសេនីយ៍ឯកបំរុង ភួង ថេតាយ (PHUNG THETAI)

២- ឯកឧត្តម CAO YUN DE

**ង-គ្រឿងឥស្សរិយយស សម្តេចព្រះមហាក្សត្រីយានី ព្រះស៊ីសុវត្ថិមុនីវង្សកុសុមៈនារីរ័ត្ន ថ្នាក់ មហាសេរីវឌ្ឍន៍**

| | | | | | |
|---|---|---|---|---|---|
| ១- | លោកស្រី | ចាំង ស៊ីណាត | ២- | លោកជំទាវ | លី ម៉ូលី |

**ច-គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេរីវឌ្ឍន៍**

| | | | | | |
|---|---|---|---|---|---|
| ១- | ឧបាសិកា | ចិន ម៉ិច | ២- | ឧបាសិកា | អ៊ុក សាម៉ុត |

**ឆ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេនា**

| | | | | | |
|---|---|---|---|---|---|
| ១- | ឧត្តមសេនីយ៍ត្រី | ខៀវ សុខា | ៨- | លោក | អឿ សារុន |
| ២- | វរសេនីយ៍ទោ | ផុន ឡេង | ៩- | លោកជំទាវ | ថា សិលាពេជ្រ |
| ៣- | វរសេនីយ៍ត្រី | សឿង សិលា អត្តលេខ ១៩៥៩៣៨ | ១០- | លោក | យ៉ាង គឹមថេង |
| ៤- | វរសេនីយ៍ឯក | អ៊ួន ចាន់ឆួច អត្តលេខ ១៩៥១៥៥ | ១១- | លោកស្រី | លី ឆៀង |
| ៥- | លោក | អឿ សារុន | ១២- | លោកស្រី | ពឹង ធីតា |
| ៦- | លោក | ជា ណារិន | ១៣- | លោកស្រី | មាស សុគន្ធា |
| ៧- | លោក | ជា ចំរើន | | | |

**ជ-គ្រឿងឥស្សរិយយស សហមេត្រី ថ្នាក់ មហាសេនា**

| | | | |
|---|---|---|---|
| ១- | Mr. RONALD L . MOORE | ២- | Ms. VINA THU . NGA LAM |

**ឈ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ ធិបឌិន្ទ**

| | | | | | |
|---|---|---|---|---|---|
| ១- | ឧត្តមសេនីយ៍ត្រី | ហូ សិទ្ធិគុណ | ៥- | លោក | ឈិន ចំរើន |
| ២- | វរសេនីយ៍ឯក | ស៊ឹង ស៊ីណា | ៦- | កញ្ញា | ព្រំ សុចិន្តា |
| ៣- | លោក | ពេជ្រ គីរុណ | ៧- | វរសេនីយ៍ត្រី | ចន្ទកេសរ អត្តលេខ ០៣០២៣៦ |
| ៤- | លោក | ខួន សុវណ្ណារ៉ា | | | |

**ញ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ សេនា**

| | | | | | |
|---|---|---|---|---|---|
| ១- | វរសេនីយ៍ទោ | យុគ ឃីម | ៤- | អនុសេនីយ៍ទោ | យូ សៅជន អត្តលេខ០៨៣៣៣ |
| ២- | អនុសេនីយ៍ឯក | ប្រាក់ ឆួច អត្តលេខ ១៦១៤០៩ | ៥- | អនុសេនីយ៍ទោ | មិនសម្បត្តិ អត្តលេខ ៣៤៣៤១ |
| ៣- | អនុសេនីយ៍ឯក | គឹម ចាន់សៅ អត្តលេខ ២៣១៥៨២ | ៦- | អនុសេនីយ៍ទោ | សេកស៊ីថា អត្តលេខ ៣៤៣៣៤ |

**ដ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ អស្សឫទ្ធិ**

| | | | | | |
|---|---|---|---|---|---|
| ១- | អនុសេនីយ៍ឯក | សួន ចន្ទ្រាបុត្រ អត្តលេខ ០៦៣៣៤៩ | ៣- | អនុសេនីយ៍ឯក | ចន សុភា អត្តលេខ ០៣៧៥៩១ |
| ២- | អនុសេនីយ៍ឯក | សាន សុភា អត្តលេខ ១៦៣១៩៥ | ៤- | អនុសេនីយ៍ឯក | ហួយ សាវឿន អត្តលេខ ០៦៣០៥៧ |

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣៧៤.១៣០២.១៨៣

លេខ ១៧៥ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០១៣
អគ្គលេខាធិការរងនៃទីស្តីការគណៈរដ្ឋមន្ត្រី

...យ សុខា

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ ២០១៣

# ព្រះរាជក្រឹត្យ

នស/រកត/០២១៣/១៦៣

យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

ប្រោសព្រះរាជទាន

ចំពោះ

មន្ត្រីរាជការនៃក្រសួងកិច្ចការនារី ចំនួន០៤រូប
មានស្នាដៃល្អក្នុងការបំពេញភារកិច្ចបំរើជាតិមាតុភូមិ កន្លងមក

នូវ

**ក-គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេរីវឌ្ឍន៍**
លោកស្រី ឱ សុខុម

**ខ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេនា**
លោកស្រី ហេង ស៊ីថុន

**គ-គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា**
លោកស្រី នួច ស៊ីថុល

**ឃ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ សេនា**
លោកស្រី ជូ សុខផានី

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣៧៣. ១៣០៤. ១៦៤

លេខ: ១៥៨ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី១ ខែមីនា ឆ្នាំ២០១៣
អគ្គលេខាធិការរងទីស្តីការគណៈរដ្ឋមន្ត្រី

ធ្វើនៅព្រះបរមរាជវាំង , ថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ ២០១៣

សុខា

# ព្រះរាជក្រឹត្យ

នស/រកត/០២១៣/១៦៤

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ចំពោះ

ថ្នាក់ដឹកនាំ និង មន្ត្រីរាជការ នៃខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី ចំនួន ០៨រូប មានស្នាដៃល្អ និងគុណបំណាច់ខ្ពស់
ក្នុងការបំពេញភារកិច្ច បម្រើជាតិមាតុភូមិកន្លងមក ទទួលបានលទ្ធផលល្អប្រសើរ

នូវ

ក-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេរីវឌ្ឍន៍
១- ឯកឧត្តម ឌួង រតនា ២- ឯកឧត្តម លី សុខហេង
ខ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេនា
- លោកជំទាវ សួរ ដាវ៉ា
គ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ សេនា
១- ឯកឧត្តម ហេង សូរិទ្ធ ៣- ឯកឧត្តម ឆាន សំណាង
២- ឯកឧត្តម ម៉ៅ និត្យារុណ
ឃ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ អស្សរិទ្ធិ
១- លោកស្រី ព្រាប កែវចន្ទមុនី ២- លោកស្រី ម៉ែន ចន្ទជាទី

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

លេខ: ១៥០ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ២០១៣
អគ្គលេខាធិការរងទីស្តីការគណៈរដ្ឋាភិបាល
សុខា

១៩៨០.១៣០២.១៦៥

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ២០១៣

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៦៦. អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ការរៀបចំនិងការប្រព្រឹត្តទៅ
# របស់អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីអភិវឌ្ឍយុវជន

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣២ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអប់រំ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២១៣/១៤១ ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីអភិវឌ្ឍយុវជន
- បានឃើញអនុក្រឹត្យលេខ៨៤ អនក្រ.បក ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០០៩ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី១៨ ខែមករា ឆ្នាំ២០១៣

## សម្រេច

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

អនុក្រឹត្យនេះកំណត់អំពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីអភិវឌ្ឍយុវជន ដែលហៅកាត់ថាអគ្គលេខាធិការដ្ឋាន**ក.ជ.យ.**។

## ជំពូកទី២
## តួនាទីនិងភារកិច្ច

**មាត្រា ២.-**

អគ្គលេខាធិការដ្ឋាន**ក.ជ.យ.** មានតួនាទីជាសេនាធិការជូន**ក.ជ.យ.** និងមានភារកិច្ចដូចខាងក្រោម៖

- គ្រប់គ្រងកិច្ចការរដ្ឋបាល ផែនការ ហិរញ្ញវត្ថុ និងបច្ចេកទេសដើម្បីធានាបាននូវការប្រព្រឹត្តទៅប្រកបដោយនិរន្តរភាពរបស់**ក.ជ.យ.**
- រៀបចំនិងប្រមូលផ្តុំផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពជាតិដើម្បីអភិវឌ្ឍយុវជនកម្ពុជា
- រៀបចំគម្រោងថវិកាប្រចាំឆ្នាំរបស់**ក.ជ.យ.**
- រៀបចំនិងបង្កើតកម្មវិធីនិងសេវានានាដើម្បីឆ្លើយតបទៅនឹងយុទ្ធសាស្ត្ររបស់គោលនយោបាយជាតិស្តីពីការអភិវឌ្ឍយុវជនកម្ពុជា
- សម្របសម្រួលលើកកម្ពស់អន្តរកម្មនិងការងារជាបណ្តាញក្នុងចំណោមស្ថាប័នរដ្ឋ ស្ថាប័នឯកជន អង្គការជាតិ អង្គការអន្តរជាតិ និងអ្នកពាក់ព័ន្ធ
- រៀបចំការប្រជុំ សន្និសីទ ការបណ្តុះបណ្តាល សិក្ខាសាលា និងការផ្សព្វផ្សាយដែលពាក់ព័ន្ធនឹងការអភិវឌ្ឍយុវជន
- ផ្តល់ព័ត៌មានថ្មីៗចុងក្រោយទាន់សភាពការណ៍អំពីយុទ្ធសាស្ត្រសំខាន់ៗដើម្បីអភិវឌ្ឍយុវជន
- ជំរុញនិងតាមដានការអនុវត្តច្បាប់និងលិខិតបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធនឹងការអភិវឌ្ឍយុវជន
- សិក្សាស្រាវជ្រាវ តាមដាន ត្រួតពិនិត្យ វាយតម្លៃ និងជំរុញការអនុវត្តគោលនយោបាយជាតិស្តីពីការអភិវឌ្ឍយុវជនកម្ពុជា
- លើកសំណើពិនិត្យនិងកែលម្អគោលនយោបាយជាតិស្តីពីការអភិវឌ្ឍយុវជនកម្ពុជា និងផែនការសកម្មភាពជាតិស្តីពីការអភិវឌ្ឍយុវជនកម្ពុជាជូន**ក.ជ.យ**
- ធ្វើរបាយការណ៍ជូន**ក.ជ.យ.**និងស្ថាប័នពាក់ព័ន្ធជាតិនិងអន្តរជាតិ
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែល**ក.ជ.យ.**ប្រគល់ជូន។

## ជំពូកទី៣
## រចនាសម្ព័ន្ធនិងការគ្រប់គ្រង

**មាត្រា ៣.-**

អគ្គលេខាធិការដ្ឋាន**ក.ជ.យ.** ដឹកនាំដោយអគ្គលេខាធិការមួយរូបនិងមានអគ្គលេខាធិការរងមួយចំនួនតាមការចាំបាច់។

**មាត្រា ៤.-**

អគ្គលេខាធិការដ្ឋាន**ក.ជ.យ.**មានរចនាសម្ព័ន្ធដូចខាងក្រោម៖

- ផ្នែករដ្ឋបាល ផែនការ និងហិរញ្ញវត្ថុ
- ផ្នែកអនុវត្តគោលនយោបាយ
- ផ្នែកតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ។

អគ្គលេខាធិការដ្ឋាន**ក.ជ.យ.** អាចពង្រីករចនាសម្ព័ន្ធថែមទៀតតាមការចាំបាច់។

អង្គការលេខនៃអគ្គលេខាធិការដ្ឋាន**ក.ជ.យ.**ត្រូវបានភ្ជាប់ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

**មាត្រា ៥.-**

ផ្នែកនីមួយៗត្រូវដឹកនាំដោយប្រធានមួយរូបមានឋានៈស្មើប្រធាននាយកដ្ឋាននិងមានអនុប្រធានផ្នែកមួយចំនួនដែលមានឋានៈស្មើអនុប្រធាននាយកដ្ឋាន តាមការចាំបាច់។

ផ្នែកនីមួយៗរបស់អគ្គលេខាធិការដ្ឋាន**ក.ជ.យ.**អាចមានការិយាល័យចំណុះមួយចំនួនតាមការចាំបាច់។

ការរៀបចំនិងការប្រព្រឹត្តទៅរបស់ការិយាល័យចំណុះផ្នែកនីមួយៗ ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ប្រធាន**ក.ជ.យ.**។

**មាត្រា ៦.-**

អគ្គលេខាធិការដ្ឋាន**ក.ជ.យ.** មានមន្ត្រីបម្រើការមកពីក្រសួងអប់រំ យុវជន និងកីឡា និងមន្ត្រីរាជការនៅក្នុងក្របខ័ណ្ឌមុខងារសាធារណៈផ្សេងទៀត។ ក្នុងករណីចាំបាច់ អគ្គលេខាធិការដ្ឋាន**ក.ជ.យ.** អាចមានអ្នកជំនាញការនិងបុគ្គលិកជាប់កិច្ចសន្យាដើម្បីជួយបំពេញការងាររបស់ខ្លួន។

## ជំពូកទី៤
## តួនាទីនិងភារកិច្ចរបស់ផ្នែកនីមួយៗ

**មាត្រា ៧.-**

ផ្នែករដ្ឋបាល ផែនការ និងហិរញ្ញវត្ថុមានតួនាទីនិងភារកិច្ចដូចតទៅ៖

- គ្រប់គ្រងមន្ត្រីរាជការរបស់អគ្គលេខាធិការដ្ឋាន**ក.ជ.យ.**
- ផ្គត់ផ្គង់សម្ភារៈ បរិក្ខារ និងគ្រប់គ្រងឯកសាររដ្ឋបាល ចលនវត្ថុ អចលនវត្ថុ និងបញ្ជីសារពើភណ្ឌ

- រៀបចំកសាងផែនការនិងគ្រប់គ្រងហិរញ្ញវត្ថុ
- គ្រប់គ្រងស្ថិតិព័ត៌មាននិងតួលេខរបស់អង្គការស្ថាប័នដែលពាក់ព័ន្ធនឹងការងារអភិវឌ្ឍយុវជន
- ធ្វើទំនាក់ទំនងនិងសហការជាមួយផ្នែកនីមួយៗរបស់អគ្គលេខាធិការដ្ឋាន
- ធ្វើកំណត់ហេតុរាល់អង្គប្រជុំសាមញ្ញនិងវិសាមញ្ញរបស់**គ.ជ.យ.**
- ធ្វើរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំអំពីលទ្ធផល សកម្មភាពនៃការអនុវត្តគោលនយោបាយជាតិស្ដីពីការអភិវឌ្ឍយុវជនកម្ពុជា
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលអគ្គលេខាធិការ**គ.ជ.យ.** ប្រគល់ជូន។

**មាត្រា ៨.-**

**ផ្នែកអនុវត្តគោលនយោបាយមានតួនាទីនិងភារកិច្ចដូចតទៅ៖**

- សម្របសម្រួលការអភិវឌ្ឍក្របខ័ណ្ឌច្បាប់និងយន្តការផ្សេងៗ
- ជំរុញការអនុវត្តគោលនយោបាយជាតិស្ដីពីការអភិវឌ្ឍយុវជនកម្ពុជា
- រៀបចំសេចក្ដីព្រាងផែនការសកម្មភាពជាតិស្ដីពីការអភិវឌ្ឍយុវជនកម្ពុជានិងកម្មវិធីនានា
- ជំរុញនិងលើកកម្ពស់ការអប់រំ ការបណ្ដុះបណ្ដាល និងការអភិវឌ្ឍសមត្ថភាពយុវជនប្រកបដោយគំនិតច្នៃប្រឌិត
- សម្របសម្រួលនិងអនុវត្តការបណ្ដុះស្មារតីសហគ្រិនភាពនិងទីផ្សារការងារ
- សហការជាមួយក្រសួង ស្ថាប័ន គ្រឹះស្ថានសាធារណៈ និងឯកជនពាក់ព័ន្ធនានា ដើម្បីជំរុញការអនុវត្តគោលនយោបាយជាតិស្ដីពីការអភិវឌ្ឍយុវជនកម្ពុជា
- បង្កើនកិច្ចសហការដើម្បីផ្ដល់ឱកាសឱ្យយុវជនធ្វើជំនួញខ្នាតតូច មធ្យម និងខ្នាតធំ និងផ្ដល់ឥណទានក្នុងការចាប់ផ្ដើមនិងពង្រីកមុខជំនួញ
- បង្កើនការអប់រំ ការថែទាំ និងការផ្ដល់សេវាសុខភាពដល់យុវជន
- សម្របសម្រួលនិងលើកកម្ពស់កិច្ចការពារ សុវត្ថិភាព សន្តិសុខ យុត្តិធម៌ និងទប់ស្កាត់អំពើហិង្សាក្នុងចំណោមយុវជន
- សម្របសម្រួលនិងលើកកម្ពស់ការសម្រាក ការកម្សាន្តនិងកីឡា ការយល់ដឹងពីបរិស្ថាន កសិកម្ម ទេសចរណ៍ និងធុរកិច្ច
- សម្របសម្រួលទប់ស្កាត់ការប្រើប្រាស់គ្រឿងញៀន និងស្ដារយុវនីតិសម្បទាក្នុងចំណោមយុវជន
- សម្របសម្រួលនិងលើកកម្ពស់កិច្ចការពារយុត្តិធម៌និងដោះស្រាយបញ្ហាយុវជន។

- បង្កើនការចូលរួមរបស់យុវជនក្នុងដំណើរការអភិវឌ្ឍមូលដ្ឋាន សហគមន៍ និងការអភិវឌ្ឍប្រទេសជាតិ
- លើកទឹកចិត្តឱ្យយុវជនចូលរួមបំពេញការងារស្ម័គ្រចិត្តនិងលើកកម្ពស់សាមគ្គីភាព និងសមភាពយេនឌ័រ
- សហការជាមួយគ្រប់ប្រព័ន្ធព័ត៌មានដើម្បីផ្សព្វផ្សាយអំពីការអភិវឌ្ឍយុវជន ជាពិសេសការយល់ដឹងអំពីបរិស្ថាន កសិកម្ម និងទេសចរណ៍
- លើកកម្ពស់សិល្បៈ វប្បធម៌ និងការបណ្តុះបណ្តាលយុវអ្នកនិពន្ធ យុវសិល្បករដែលប្រកបដោយគំនិតច្នៃប្រឌិត
- ធ្វើរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំអំពីលទ្ធផលការងាររបស់ខ្លួន
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលអគ្គលេខាធិការ**គ.ជ.យ.**ប្រគល់ជូន។

**មាត្រា ៩.-**

**ផ្នែកតាមដាន ត្រួតពិនិត្យ និងវាយតម្លៃមានតួនាទីនិងភារកិច្ចដូចតទៅ៖**

- រៀបចំផែនការសកម្មភាព និងកំណត់សូចនាករ ដើម្បីត្រួតពិនិត្យការអនុវត្តគោលនយោបាយជាតិស្តីពីការអភិវឌ្ឍយុវជនកម្ពុជា
- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើការផ្តល់សេវាឱ្យឆ្លើយតបនឹងគោលនយោបាយជាតិស្តីពីការអភិវឌ្ឍយុវជនកម្ពុជា
- រៀបចំសេចក្តីព្រាងលិខិតបទដ្ឋានពាក់ព័ន្ធនឹងការអនុវត្តនិងការអភិវឌ្ឍគោលនយោបាយជាតិស្តីពីការអភិវឌ្ឍយុវជនកម្ពុជា
- គ្រប់គ្រងទិន្នន័យយុវជននិងវិភាគលទ្ធផលការងារ ដើម្បីកែលម្អការអនុវត្តគោលនយោបាយជាតិស្តីពីការអភិវឌ្ឍយុវជនកម្ពុជា
- សិក្សាស្រាវជ្រាវទៅលើបញ្ហាយុវជននៅក្នុងសង្គមដែលជាមូលដ្ឋានជាក់ស្តែងសម្រាប់អភិវឌ្ឍគោលនយោបាយជាតិស្តីពីការអភិវឌ្ឍយុវជនកម្ពុជា
- ធ្វើរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំអំពីលទ្ធផលការងាររបស់ខ្លួន
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលអគ្គលេខាធិការ**គ.ជ.យ.**ប្រគល់ជូន។

## ជំពូកទី៥
## អវសានប្បញ្ញត្តិ

**មាត្រា ១០.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ១១.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ប្រធានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីអភិវឌ្ឍយុវជន រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០១៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១១
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ៦៦ អនក្រ.បក ចុះថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០១៣
ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាន
នៃក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីអភិវឌ្ឍយុវជន

## អង្គការលេខនៃអគ្គលេខាធិការដ្ឋាន គ.ជ.យ.



ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:......៦៧.....អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការសំរួលមាត្រា ១ និងមាត្រា ២ នៃអនុក្រឹត្យលេខ ១៩៧ អនក្រ.បក ចុះថ្ងៃទី ០២ ខែ វិច្ឆិកា ឆ្នាំ ២០១២ ស្តីពីកាត់ដីទំហំសរុប ១.៥៧១,៨៧ ហិកតា ចេញពីគម្របព្រៃឈើ ឆ្នាំ២០០២ និងធ្វើអនុបយោគ ជាដីឯកជនរបស់រដ្ឋ ដើម្បីធ្វើប្រទានកម្មជូនប្រជាពលរដ្ឋ ដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្តែង នៅភូមិស្ទឹងឆាយជើង ភូមិស្ទឹងឆាយត្បូង ភូមិអូរតាហយ ឃុំស្ទឹងឆាយ និងភូមិសម្តេចតា ឃុំចំការហ្លួង ស្រុកកំពង់សីលា ខេត្តព្រះសីហនុ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២នសចុះថ្ងៃទី២០ខែកក្កដាឆ្នាំ១៩៩៤ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ៨៨អនក្រ.បកចុះថ្ងៃទី០១ខែធ្នូ ឆ្នាំ២០០០ស្តីពីការបង្កើតក្រុមប្រឹក្សាគោលនយោបាយដីធ្លី

- បានឃើញអនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញអនុក្រឹត្យលេខ១៤៦ អនក្រ.បកចុះថ្ងៃទី២៧ខែធ្នូ ឆ្នាំ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច
- បានឃើញអនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០៦ ស្តីពីវិធាននិងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១៩៧ អនក្រ.បក ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១២ ស្តីពីកាត់ដីទំហំសរុប ១៥៧១,៨៧ហិកតា ចេញពីគម្រប់ព្រៃឈើ ឆ្នាំ២០០២ និងធ្វើអនុបយោគ ជាដីឯកជនរបស់រដ្ឋ ដើម្បីធ្វើប្រទានកម្មជូនប្រជាពលរដ្ឋដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្តែង នៅភូមិស្ទឹងឆាយជើង ភូមិស្ទឹងឆាយត្បូង ភូមិអូរតាហាយ ឃុំស្ទឹងឆាយ និងភូមិសម្តេចតា ឃុំចំការហ្លួង ស្រុកកំពង់សីលា ខេត្តព្រះសីហនុ
- បានឃើញសារាចរលេខ ០២ សរ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៧ ស្តីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់
- តាមសំណើលេខ ០២២ សណ/១៣ ចុះថ្ងៃទី៣០ខែមករាឆ្នាំ២០១៣របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តព្រះសីហនុ
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

# សម្រេច

**មាត្រា មួយ.-**

កែសំរួលមាត្រា ១ និង មាត្រា ២ នៃអនុក្រឹត្យលេខ ១៩៧ អនក្រ.បក ចុះថ្ងៃទី០២ ខែ វិច្ឆិកា ឆ្នាំ ២០១២ ស្តីពីកាត់ដីទំហំសរុប ១៥៧១,៨៧ ហិកតា ចេញពីគម្រប់ព្រៃឈើ ឆ្នាំ២០០២ និងធ្វើអនុបយោគ ជាដីឯកជនរបស់រដ្ឋ ដើម្បីធ្វើប្រទានកម្មជូនប្រជាពលរដ្ឋដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្តែង នៅភូមិស្ទឹងឆាយជើង ភូមិស្ទឹងឆាយត្បូង ភូមិអូរតាហាយ ឃុំស្ទឹងឆាយ និងភូមិសម្តេចតា ឃុំចំការហ្លួង ស្រុកកំពង់សីលា ខេត្តព្រះសីហនុ ដូចតទៅ៖

**មាត្រា ១ ថ្មី.-**

កាត់ដីសរុបទំហំ**២១១៣,៧៩ ហិកតា**ចេញពីគម្រប់ព្រៃឈើឆ្នាំ២០០២និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋដែលស្ថិតនៅខេត្តព្រះសីហនុ ស្រុកកំពង់សិលា ក្នុងភូមិ ឃុំ និងមានទំហំដូចខាងក្រោម ៖

-**ផ្ទៃដីទំហំ ៦៦០,១៣ហិកតា** កាត់ចេញពីគម្រប់ព្រៃឈើឆ្នាំ២០០២ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋសម្រាប់ប្រទានកម្មជូនប្រជាពលរដ្ឋ នៅភូមិស្ទឹងឆាយជើង ឃុំស្ទឹងឆាយ ។

តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum wgs 1984 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធ១(ក) (ខ)នៃអនុក្រឹត្យនេះ

-**ផ្ទៃដីទំហំ ៦៨៤,០៥ហិកតា** កាត់ចេញពីគម្រប់ព្រៃឈើឆ្នាំ២០០២ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋសម្រាប់ប្រទានកម្មជូនប្រជាពលរដ្ឋ នៅភូមិស្ទឹងឆាយត្បូង ឃុំស្ទឹងឆាយ ។

តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum wgs 1984 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធ២នៃអនុក្រឹត្យនេះ

-**ផ្ទៃដីទំហំ ២៥០,៥១ ហិកតា** កាត់ចេញពីគម្រប់ព្រៃឈើឆ្នាំ២០០២ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋសម្រាប់ប្រទានកម្មជូនប្រជាពលរដ្ឋ នៅភូមិអូរតាហាយ ឃុំស្ទឹងឆាយ ។

តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum wgs 1984 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធ៣ នៃអនុក្រឹត្យនេះ

-**ផ្ទៃដីទំហំ ៥១៩,១២ ហិកតា** កាត់ចេញពីគម្រប់ព្រៃឈើឆ្នាំ២០០២ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋសម្រាប់ប្រទានកម្មជូនប្រជាពលរដ្ឋ នៅភូមិសម្តេចតា ឃុំចំការហ្លួង ។

តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum wgs 1984 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធ៤ នៃអនុក្រឹត្យនេះ

**មាត្រា ២ ថ្មី.-**

ប្រគល់អាណត្តិកាន់កាប់និងបែងចែកដីឯកជនរបស់រដ្ឋដូចមានចែងក្នុងមាត្រា ១ ជូន គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តព្រះសីហនុ ដើម្បីធ្វើការគ្រប់គ្រង និងប្រទានកម្មដោយផ្តល់ជាកម្មសិទ្ធិ ជូនប្រជាពលរដ្ឋចំនួន ៣៧៩ គ្រួសារ ដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្តែង នៅស្រុកកំពង់សិលា ខេត្តព្រះសីហនុ ក្នុងភូមិ ឃុំ ដូចខាងក្រោម ៖

- សម្រាប់ប្រទានកម្មជាសិទ្ធិកម្មសិទ្ធិជូនប្រជាពលរដ្ឋចំនួន១៣១គ្រួសារនៅភូមិស្ទឹងឆាយជើង ឃុំស្ទឹងឆាយ ។
- សម្រាប់ប្រទានកម្មជាសិទ្ធិកម្មសិទ្ធិជូនប្រជាពលរដ្ឋចំនួន១៤៨គ្រួសារនៅភូមិស្ទឹងឆាយត្បូង ឃុំស្ទឹងឆាយ ។
- សម្រាប់ប្រទានកម្មជាសិទ្ធិកម្មសិទ្ធិជូនប្រជាពលរដ្ឋចំនួន ២៩ គ្រួសារ នៅភូមិអូរតាហាយ ឃុំស្ទឹងឆាយ ។
- សម្រាប់ប្រទានកម្មជាសិទ្ធិកម្មសិទ្ធិជូនប្រជាពលរដ្ឋចំនួន ៧១គ្រួសារ នៅភូមិសម្តេចតា ឃុំចំការហ្លួង ។

**មាត្រា ពីរ .-**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា បី.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាល ខេត្តព្រះសីហនុ ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ២០១៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

*កន្លែងទទួល*

- *ក្រសួងព្រះបរមរាជវាំង*
- បានឃើញអនុក្រឹត្យលេខ២៧អនក្រ.បក ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិវាយតម្លៃទីក្រុងស្អាត
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងទេសចរណ៍និងជាប្រធានគណៈកម្មាធិការជាតិវាយតម្លៃទីក្រុងស្អាត

## សម្រេច

**ប្រការ ១.-**

ត្រូវបានកំណត់យុទ្ធនាការ "ទេសចរម្នាក់ ដើមឈើមួយដើម" សំដៅជំរុញសកម្មភាពដាំដើមឈើ នៅតាមទីក្រុង ទីប្រជុំជន រមណីយដ្ឋានទេសចរណ៍ ក្រុមហ៊ុន រោងចក្រ សហគ្រាស សហគមន៍-

ទេសចរណ៍ ឬទីតាំងសមស្របនានា ដើម្បីប្រែក្លាយជាផលិតផលទេសចរណ៍ដ៏ទាក់ទាញ ដែលអាចផ្តល់បទពិសោធន៍ថ្មីៗដល់ភ្ញៀវទេសចរជាតិនិងអន្តរជាតិ។

**ប្រការ ២.-**

ដើម្បីជានាឲ្យយុទ្ធនាការ "ទេសចរម្នាក់ ដើមឈើមួយដើម" ក្លាយជាផលិតផលទេសចរណ៍មួយប្រកបដោយគុណភាពនិងភាពទាក់ទាញ រាល់ទីតាំងដែលបម្រើឲ្យយុទ្ធនាការនេះត្រូវគោរពតាមស្តង់ដា "សួនទេសចរណ៍"។

ស្តង់ដា "សួនទេសចរណ៍" ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទេសចរណ៍ និងជាប្រធានគណៈកម្មាធិការជាតិវាយតម្លៃទីក្រុងស្អាត។

**ប្រការ ៣.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះត្រូវទុកជានិរាករណ៍។

**ប្រការ ៤.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងទេសចរណ៍ និងជាប្រធានគណៈកម្មាធិការជាតិវាយតម្លៃទីក្រុងស្អាត រដ្ឋមន្ត្រី រដ្ឋលេខាធិការក្រសួង-ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ២០១៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

***កន្លែងទទួល៖***

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចប្រការ៤*
- *រាជកិច្ច*
- *ឯកសារកាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ១៣៦ សហវ.ប្រក

រាជធានីភ្នំពេញ, ថ្ងៃទី ២៩ ខែ មករា ឆ្នាំ ២០១៣

# ប្រកាសរួម
# ស្តីពី
# ការផ្តល់សេវាសាធារណៈរបស់ក្រសួងព្រះបរមរាជវាំង

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
## ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំង

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ NS / KRT - 34 ចុះថ្ងៃទី២៧ ខែឧសភា ឆ្នាំ១៩៩៦ ត្រាស់បង្គាប់បង្កើតក្រសួងព្រះបរមរាជវាំង
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០០ និងអនុក្រឹត្យពាក់ព័ន្ធ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St,92, Sangkat Wat Phnom , khan Daun Penh, Phnom Penh, CAMBODIA.
www.mef.gov.kh
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798
mef_adm@yahoo.com

- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញបទបញ្ជាលេខ ០៤ បប. ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០០៦ របស់រាជរដ្ឋាភិបាល ស្តីពីការពង្រឹងការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ
- ប្រកាសលេខ ២៧២ សហវ.ប្រក ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១១ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការដាក់ឱ្យប្រើប្រាស់បង្កាន់ដៃបង់ប្រាក់
- សារាចរណែនាំលេខ ០០៥ សហវ ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១១ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការគ្រប់គ្រងបង្កាន់ដៃបង់ប្រាក់
- តាមការចាំបាច់របស់ក្រសួងព្រះបរមរាជវាំង និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ ១** :

អនុញ្ញាតឱ្យក្រសួងព្រះបរមរាជវាំង អនុវត្តការប្រមូលចំណូលពីការលក់សំបុត្រចូលទស្សនាព្រះបរមរាជវាំង ដើម្បីជាគុណប្រយោជន៍ថវិកាជាតិ។

តម្លៃសំបុត្រចូលទស្សនាព្រះបរមរាជវាំង រយៈពេលផ្តល់ និងសុពលភាព ត្រូវកំណត់ ដូចខាងក្រោម ៖

| ល.រ | បរិយាយ | តម្លៃសេវា | រយៈពេលផ្តល់សេវា | សុពលភាព |
|---|---|---|---|---|
| 1 | សំបុត្រចូលទស្សនាព្រះបរមរាជវាំង សម្រាប់ជនជាតិខ្មែរ | 1,000 រៀល | ភ្លាមៗ | 1 ថ្ងៃ |
| 2 | សំបុត្រចូលទស្សនាព្រះបរមរាជវាំង សម្រាប់ជនបរទេស | 25,000 រៀល | ភ្លាមៗ | 1 ថ្ងៃ |

**ប្រការ ២** :

ក្រសួងព្រះបរមរាជវាំង ត្រូវបិទផ្សាយជាសាធារណៈនូវប្រកាសរួម នៅនឹងកន្លែងផ្តល់សេវា។

ក្រសួងព្រះបរមរាជវាំង ត្រូវរៀបចំឱ្យមានកន្លែងទទួលបណ្តឹងតវ៉ា ដែលអាចកើតមានឡើងដោយថាហេតុជាពិសេសក្នុងករណីមានការអនុវត្តខុសពីស្តង់ដារ ឬមានការយកកម្រៃលើសការកំណត់ ឬមានការយឺតយ៉ាវជាដើម។

**ប្រការ ៣ :**

ក្រសួងព្រះបរមរាជវាំង មានភារកិច្ចប្រមូលចំណូល ទទួលខុសត្រូវប្រាក់ចំណូលដែលប្រមូលបាន និង បង់ប្រាក់ចំណូលចូលថវិកាជាតិ ក្នុងនោះ ត្រូវចុះកិច្ចបញ្ជិកាគណនេយ្យ ស្ដីពីកិច្ចប្រតិបត្តិការចំណូល និងកត់ត្រា តាមដានប្រាក់ចំណូលនៅក្នុងជំពូក គណនី អនុគណនី នៃមាតិកាថវិកា ព្រមទាំងធ្វើសលាកប័ត្រចំណូល។

**ប្រការ ៤ :**

រាល់ការប្រមូលចំណូលពីការលក់សំបុត្រចូលទស្សនាព្រះបរមរាជវាំង ដូចបានកំណត់ក្នុងប្រការ១ នៃ ប្រកាសរួមនេះ ត្រូវប្រើប្រាស់បង្កាន់ដៃបង់ប្រាក់ ដែលបានបើកផ្ដល់ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្របតាម ប្រកាសលេខ ២៧២ សហវ.ប្រក ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១១ ស្ដីពីការដាក់ឱ្យប្រើប្រាស់បង្កាន់ដៃបង់ប្រាក់ និងសារាចរណែនាំលេខ ០០៥ សហវ ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១១ ស្ដីពីការគ្រប់គ្រងបង្កាន់ដៃបង់ប្រាក់ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**ប្រការ ៥ :**

ក្រសួងព្រះបរមរាជវាំង ត្រូវកំណត់ទីតាំងដាក់លាក់ និងមានមន្ត្រីប្រចាំការនៅទីតាំងដែលបានកំណត់ ដើម្បីទទួលបម្រើសេវាជូនអតិថិជនឱ្យបានទាន់ពេលវេលា តាមការកំណត់។

**ប្រការ ៦ :**

ក្រសួងព្រះបរមរាជវាំង ត្រូវធ្វើរបាយការណ៍ ស្ដីពីការអនុវត្តចំណូលប្រចាំខែ និងប្រចាំឆ្នាំ ដើម្បីផ្ញើមក ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឱ្យបានមុនថ្ងៃទី១០ នៃខែបន្ទាប់ សម្រាប់របាយការណ៍ប្រចាំខែ និងឱ្យបានមុនថ្ងៃ ទី១៥ ខែមករា នៃឆ្នាំបន្ទាប់ សម្រាប់របាយការណ៍ប្រចាំឆ្នាំ។

**ប្រការ ៧ :**

តម្លៃសំបុត្រចូលទស្សនាព្រះបរមរាជវាំង ដែលបានកំណត់ក្នុងប្រការ១ នៃប្រកាសរួមនេះ អាចកែប្រែបាន តាមការចាំបាច់តាមរយៈប្រកាសរួម។

**ប្រការ ៨ :**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសរួមនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ៩ :**

អគ្គលេខាធិការ នាយកខុទ្ទកាល័យ អគ្គនាយក ប្រធាននាយកដ្ឋាន និងប្រធានអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រោមឱវាទក្រសួងព្រះបរមរាជវាំង ត្រូវទទួលបន្ទុកអនុវត្តប្រកាសរួមនេះឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ៕

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**គាត ឈន់**

**ឧបនាយករដ្ឋមន្ត្រី**
**និងជារដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំង**

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

សម្តេចចៅហ្វាវាំង វរវៀងជ័យ អធិបតីស្រីឧ្ញារ **គង់ សំអុល**

**ចម្លងជូន:**

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី
- អាជ្ញាធរសវនកម្មជាតិ
- ក្រសួង ស្ថាប័នពាក់ព័ន្ធ
- អង្គភាពប្រឆាំងអំពើពុករលួយ
- គ្រប់រដ្ឋបាលរាជធានី ខេត្ត
- សភាពាណិជ្ជកម្មកម្ពុជា

«ដើម្បីជូនជ្រាប»

- ដូចប្រការ ៩ «ដើម្បីមុខការ»
- ឯកសារ - កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

MINISTRY OF ECONOMY AND FINANCE

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ១៣៣ សហវ.ប្រក

រាជធានីភ្នំពេញ, ថ្ងៃទី ២៩ ខែ មករា ឆ្នាំ ២០១៣

# ប្រកាសរួម
# ស្តីពី
# ការផ្តល់ទ្រាន់លើកទឹកចិត្តជូន
# ក្រសួងព្រះបរមរាជវាំង និង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
## ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំង

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ NS / KRT - 34 ចុះថ្ងៃទី២៧ ខែឧសភា ឆ្នាំ១៩៩៦ ត្រាស់បង្គាប់បង្កើតក្រសួងព្រះបរមរាជវាំង
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០០ និងអនុក្រឹត្យពាក់ព័ន្ធ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St,92, Sangkat Wat Phnom , khan Daun Penh, Phnom Penh, CAMBODIA.
www.mef.gov.kh
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798
mef_adm@yahoo.com

- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញបទបញ្ជាលេខ ០៤ បប. ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០០៦ របស់រាជរដ្ឋាភិបាល ស្តីពីការពង្រឹងការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ
- យោងប្រកាសរួមលេខ ១៣២ សហវ.ប្រក ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៣ ស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងព្រះបរមរាជវាំង

## សម្រេច

**ប្រការ ១** :

ត្រូវបានផ្តល់ប្រាក់រង្វាន់លើកទឹកចិត្ត ជូនក្រសួងព្រះបរមរាជវាំង និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សម្រាប់ឧបត្ថម្ភជូនមន្ត្រីដែលបំពេញភារកិច្ចផ្ទាល់ និងមន្ត្រីផ្សេងៗទៀត លើការបម្រើសេវាសាធារណៈ ព្រមទាំងសម្រាប់ពង្រឹងយន្តការប្រមូលចំណូល។

**ប្រការ ២** :

អនុញ្ញាតឱ្យក្រសួងព្រះបរមរាជវាំង កាត់ទុកជាមុននូវចំណែកប្រាក់រង្វាន់ ដោយដកយកពីប្រាក់ចំណូលដែលប្រមូលបានពីការផ្តល់សេវាសាធារណៈ ដូចបានកំណត់ដោយប្រកាសរួមលេខ ១៣២ សហវ.ប្រក ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៣ ស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងព្រះបរមរាជវាំង។ ការកាត់ទុកជាមុននូវចំណែកប្រាក់រង្វាន់នេះ ត្រូវបានចាត់ទុកថា ថវិកាជាតិបានបើកផ្តល់ជាប្រាក់បុរេប្រទានជូនក្រសួងព្រះបរមរាជវាំង សម្រាប់ការចំណាយឧបត្ថម្ភជូនមន្ត្រី និងពង្រឹងយន្តការប្រមូលចំណូល ដែលបានកំណត់នៅក្នុងប្រការ១ នៃប្រកាសរួមនេះ។ ប្រាក់រង្វាន់ដែលអនុញ្ញាតឱ្យកាត់ទុកជាមុននេះ រួមមានចំណែកប្រាក់រង្វាន់របស់ក្រសួងព្រះបរមរាជវាំង និងចំណែកប្រាក់រង្វាន់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**ប្រការ ៣** :

ការផ្តល់ប្រាក់រង្វាន់ជូនក្រសួងព្រះបរមរាជវាំង និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវបានកំណត់ជាសមាមាត្រភាគរយធៀបទៅនឹងប្រាក់ចំណូលប្រមូលបាន និងត្រូវបានបែងចែក ដូចខាងក្រោម ៖

- បង់ចូលថវិកាជាតិ ចំនួន ៣០% នៃចំណូលដែលប្រមូលបាន
- ជូនក្រសួងព្រះបរមរាជវាំង ចំនួន ៦៩% នៃចំណូលដែលប្រមូលបាន
- ជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ចំនួន ១% នៃចំណូលដែលប្រមូលបាន

**ប្រការ ៤** :

ក្រសួងព្រះបរមរាជវាំង ត្រូវគ្រោងចំណូល និងចំណាយដែលជាកម្មវត្ថុសម្រាប់ការផ្តល់ប្រាក់រង្វាន់លើកទឹកចិត្ត នៅក្នុងគម្រោងចំណូល និងចំណាយនៃថវិកាប្រចាំឆ្នាំរបស់ខ្លួន។ ក្រសួងព្រះបរមរាជវាំង ត្រូវគ្រោងឥណទានប្រាក់រង្វាន់ ដោយគិតបញ្ចូលរួមទាំងឥណទានសម្រាប់ការចំណាយលើប្រាក់រង្វាន់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

រាល់ប្រតិបត្តិការនៃចំណូល និងចំណាយទាំងនេះ ត្រូវកត់ត្រាឆ្លុះបញ្ចាំងក្នុងថវិកាជាតិ ដូចប្រតិបត្តិការនៃចំណូល និងចំណាយដទៃទៀតរបស់ក្រសួងព្រះបរមរាជវាំងដែរ។ ឥណទានដែលបានគ្រោងសម្រាប់ការចំណាយលើប្រាក់រង្វាន់នេះ ជាកម្មវត្ថុនៃការធ្វើអាណត្តិបើកប្រាក់ ដើម្បីទូទាត់ជាមួយចំនួនទឹកប្រាក់ដែលចាត់ទុកថាបានបុរេប្រទានពីថវិកាជាតិ(ប្រាក់ចំណូលដែលបានកាត់ទុកជាមុន)។

ការកត់ត្រាចំណូល និងចំណាយក្នុងកិច្ចប្រតិបត្តិការថវិកាជាតិ លើការផ្តល់ប្រាក់រង្វាន់លើកទឹកចិត្ត ត្រូវអនុវត្តតាមនីតិវិធីទូទាត់ប្រាក់បុរេប្រទាន ដូចខាងក្រោម ៖

ក. **ផ្នែកចំណូល**: ត្រូវធ្វើសលាកប័ត្រចំណូលថវិកាជាតិ នូវចំនួនទឹកប្រាក់ដែលបានបុរេប្រទាន ៖ ក្រសួងព្រះបរមរាជវាំង ត្រូវរៀបចំ និងបញ្ជូនសលាកប័ត្រចំណូលថវិកាជាតិ មកនាយកដ្ឋានចំណូលមិនមែនសារពើពន្ធ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយភ្ជាប់មកជាមួយនូវរបាយការណ៍ស្ថានភាព ស្តីពីការអនុវត្តចំណូល និងតារាង ស្តីពីការគណនាប្រាក់រង្វាន់ ព្រមទាំងរបាយការណ៍ ស្តីពីការបែងចែកប្រាក់រង្វាន់ដែលបានបើកផ្តល់កន្លងមក។ នាយកដ្ឋានចំណូលមិនមែនសារពើពន្ធ ត្រូវចេញលិខិតពិនិត្យបញ្ជាក់លើចំនួនទឹកប្រាក់ដែលបានចុះក្នុងសលាកប័ត្រ។

ខ. **ផ្នែកចំណាយ**: ត្រូវធ្វើអាណត្តិបើកប្រាក់ ដោយចុះចំនួនទឹកប្រាក់ស្មើនឹងចំនួនទឹកប្រាក់បុរេប្រទានដែលបានចុះនៅក្នុងសលាកប័ត្រចំណូលថវិកាជាតិ។

**ប្រការ ៥** :

ក្រោយពីបានបំពេញនីតិវិធី ដែលមានចែងក្នុងប្រការ ៤ ខាងលើ ការបើកផ្តល់ប្រាក់រង្វាន់លើកទឹកចិត្ត ត្រូវអនុវត្ត ដូចខាងក្រោម ៖

ក. ការបើកផ្តល់ប្រាក់រង្វាន់ជូនមន្ត្រីរាជការនៃក្រសួងព្រះបរមរាជវាំង ត្រូវអនុលោមតាមការសម្រេចរបស់រដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំង ដោយឈរលើគោលការណ៍សមធម៌ និងផ្អែកតាមគុណសម្បត្តិការងារ។

ខ. ការបើកផ្តល់ប្រាក់រង្វាន់ជូនមន្ត្រីរាជការនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវអនុលោមតាមការសម្រេចរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយឈរលើគោលការណ៍សមធម៌ និងផ្អែកតាមគុណសម្បត្តិការងារ។

**ប្រការ ៦** :

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសរួមនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ៧** :

អគ្គលេខាធិការ នាយកខុទ្ទកាល័យ អគ្គនាយក ប្រធាននាយកដ្ឋាន និងប្រធានអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រោមឱវាទក្រសួងព្រះបរមរាជវាំង ត្រូវទទួលបន្ទុកអនុវត្តប្រកាសរួមនេះឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**គាត ឈន់**

**ឧបនាយករដ្ឋមន្ត្រី**
**និងជារដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំង**

សម្តេចចៅហ្វាវាំង វរវៀងជ័យ អធិបតីស្រីធ្លារ **គង់ សំអុល**

ចម្លងជូនៈ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី
- អាជ្ញាធរសវនកម្មជាតិ
- អង្គភាពប្រឆាំងអំពើពុករលួយ
- គ្រប់រដ្ឋបាលរាជធានី ខេត្ត

«ដើម្បីជូនជ្រាប»
- ដូចប្រការ ៧ «ដើម្បីមុខការ»
- ឯកសារ - កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

MINISTRY OF ECONOMY AND FINANCE

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ០៣៣៤ សហវ.ប្រក

រាជធានីភ្នំពេញ, ថ្ងៃទី ២៩ ខែ មករា ឆ្នាំ ២០១៣

# ប្រកាសរួម
## ស្តីពី
## ការផ្តល់សេវាសាធារណៈរបស់រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល

### ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
### រដ្ឋលេខាធិការ រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០០ និងអនុក្រឹត្យពាក់ព័ន្ធ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ១៨ អនក្រ.បក ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St,92, Sangkat Wat Phnom , khan Daun Penh, Phnom Penh, CAMBODIA.
www.mef.gov.kh
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798
mef_adm@yahoo.com

- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញបទបញ្ជាលេខ ០៤ បប. ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០០៦ របស់រាជរដ្ឋាភិបាល ស្តីពីការពង្រឹងការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ
- ប្រកាសលេខ ២៧២ សហវ.ប្រក ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១១ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការដាក់ឱ្យប្រើប្រាស់បង្កាន់ដៃបង់ប្រាក់
- សារាចរណែនាំលេខ ០០៥ សហវ ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១១ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការគ្រប់គ្រងបង្កាន់ដៃបង់ប្រាក់
- តាមការចាំបាច់របស់រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## ស ម្រេ ច

**ប្រការ ១** :

អនុញ្ញាតឱ្យរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល អនុវត្តការប្រមូលចំណូលពីកម្រៃសេវាសាធារណៈ ដើម្បីជាគុណប្រយោជន៍ថវិកាជាតិ។

កម្រងសេវាសាធារណៈនេះ មានបញ្ជាក់លម្អិតអំពីតម្លៃសេវា រយៈពេលផ្តល់សេវា និងសុពលភាព ទៅតាមប្រភេទសេវាសាធារណៈនីមួយៗ ដូចមានចែងនៅក្នុងតារាងឧបសម្ព័ន្ធភ្ជាប់មកជាមួយនឹងប្រកាសរួមនេះ។

**ប្រការ ២** :

រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល ត្រូវបិទផ្សាយជាសាធារណៈ ជាពិសេសនៅកន្លែងផ្តល់សេវា នូវស្តង់ដារសេវា ក្នុងនោះរួមមាន ៖ តារាងតម្លៃ ទម្រង់ឯកសារ និងនីតិវិធីសម្រាប់ការផ្តល់សេវា ពាក់ព័ន្ធនឹងការប្រមូលចំណូលខាងលើនេះ។

រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល ត្រូវរៀបចំឱ្យមានកន្លែងទទួលបណ្តឹងតវ៉ា ដែលអាចកើតមានឡើងដោយថាហេតុ ជាពិសេសក្នុងករណីមានការអនុវត្តខុសពីស្តង់ដារសេវា ឬមានការយកកម្រៃលើសការកំណត់ ឬមានការយឺតយ៉ាវ ជាដើម។

**ប្រការ ៣** :

រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល មានភារកិច្ចប្រមូលចំណូល ទទួលខុសត្រូវប្រាក់ចំណូលដែលប្រមូលបាន និងបង់ប្រាក់ចំណូលចូលថវិកាជាតិ ក្នុងនោះ ត្រូវចុះកិច្ចបញ្ជិកាគណនេយ្យ ស្តីពីកិច្ចប្រតិបត្តិការចំណូល និងកត់ត្រាតាមដានប្រាក់ចំណូលនៅក្នុងជំពូក គណនី អនុគណនី នៃមាតិកាថវិកា ព្រមទាំងធ្វើសលាកប័ត្រចំណូល។

**ប្រការ ៤ :**

ការបែងចែកភារកិច្ចលើការគ្រប់គ្រង ការប្រមូលចំណូលពីការផ្តល់សេវាសាធារណៈរបស់រដ្ឋលេខាធិការ-ដ្ឋានអាកាសចរស៊ីវិល ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល។ រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល ត្រូវផ្ញើសេចក្តីប្រកាសនេះចំនួនមួយច្បាប់ជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីជូនជ្រាបជាព័ត៌មាន និងសម្រាប់តាមដានការអនុវត្តចំណូល។

**ប្រការ ៥ :**

រាល់ការប្រមូលចំណូលពីកម្រៃសេវាសាធារណៈ ដូចមានចែងនៅក្នុងតារាងឧបសម្ព័ន្ធភ្ជាប់មកជាមួយប្រកាសរួមនេះ ត្រូវប្រើប្រាស់បង្កាន់ដៃបង់ប្រាក់ ដែលបានបើកផ្តល់ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្របតាមប្រកាសលេខ ២៧២ សហវ.ប្រក ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១១ ស្តីពីការដាក់ឱ្យប្រើប្រាស់បង្កាន់ដៃបង់ប្រាក់ និងសារាចរណែនាំលេខ ០០៥ សហវ ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១១ ស្តីពីការគ្រប់គ្រងបង្កាន់ដៃបង់ប្រាក់ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**ប្រការ ៦ :**

រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល ត្រូវកំណត់ទីតាំងដាក់លាក់ និងមានមន្ត្រីប្រចាំការដែលមានលក្ខណៈជាច្រកចេញចូលតែមួយ នៅទីតាំងដែលបានកំណត់ ដើម្បីទទួលបម្រើសេវាជូនអតិថិជនឱ្យបានទាន់ពេលវេលាតាមការកំណត់។

**ប្រការ ៧ :**

រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល ត្រូវធ្វើរបាយការណ៍ ស្តីពីការអនុវត្តចំណូលប្រចាំខែ និងប្រចាំឆ្នាំ ដើម្បីផ្ញើមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឱ្យបានមុនថ្ងៃទី១០ នៃខែបន្ទាប់ សម្រាប់របាយការណ៍ប្រចាំខែ និងឱ្យបានមុនថ្ងៃទី១៥ ខែមករា នៃឆ្នាំបន្ទាប់ សម្រាប់របាយការណ៍ប្រចាំឆ្នាំ។

**ប្រការ ៨ :**

កម្រងសេវាសាធារណៈ ដូចមានចែងនៅក្នុងតារាងឧបសម្ព័ន្ធនៃប្រកាសរួមនេះ អាចកែប្រែបាន តាមការចាំបាច់តាមរយៈប្រកាសរួម។

**ប្រការ ៩ :**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសរួមនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ១០ :**

អគ្គលេខាធិការ នាយកខុទ្ទកាល័យ អគ្គនាយក ប្រធាននាយកដ្ឋាន និងប្រធានអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រោមឱវាទរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល ត្រូវទទួលបន្ទុកអនុវត្តប្រកាសរួមនេះ ឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**គាត ឈន់**

**រដ្ឋលេខាធិការ**
**រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល**

**ម៉ៅ ហាវណ្ណាល់**

ចម្លងជូន:
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី
- អាជ្ញាធរសវនកម្មជាតិ
- ក្រសួង ស្ថាប័នពាក់ព័ន្ធ
- អង្គភាពប្រឆាំងអំពើពុករលួយ
- គ្រប់រដ្ឋបាលរាជធានី ខេត្ត
- សភាពាណិជ្ជកម្មកម្ពុជា

«ដើម្បីជូនជ្រាប»
- ដូចប្រការ ១០ «ដើម្បីអនុវត្ត»
- ឯកសារ - កាលប្បវត្តិ

**តារាងឧបសម្ព័ន្ធ**

**ភ្ជាប់នឹងប្រកាសរួមលេខ ១៣៤ សហវ.ប្រក ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៣**

**ស្ដីពីការផ្ដល់សេវាសាធារណៈរបស់រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល**

| ល.រ | បរិយាយ | តម្លៃសេវា (ដុល្លារអាមេរិក) | រយៈពេលផ្ដល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|
| I | **នាយកដ្ឋានស្តង់ដា និងសុវត្ថិភាពអាកាសយានដ្ឋាន** | | | |
| 1 | ចេញវិញ្ញាបនបត្រប្រកបអាជីវកម្មអាកាសយានដ្ឋាន ( Airport Certificate ) សម្រាប់: | | | |
| 1.1 | អាកាសយានដ្ឋានអន្តរជាតិ ( International Airport ) | 15,000 $ /ឆ្នាំ | -ចេញវិញ្ញាបនបត្រថ្មី 6ខែ, ចេញឡើងវិញ 3ខែ - រយៈពេលវិញ្ញាបនបត្រ អាចអាស្រ័យតាមពេលវេលាដែលអតិថិជនអាចកែតម្រូវកង្វះខាតការងារ ( Corrective Action ) តបតាមស្តង់ដា និងបទបញ្ញត្តិអាកាសចរស៊ីវិល ) | 5ឆ្នាំ |
| 1.2 | អាកាសយានដ្ឋានមូលដ្ឋាន ( Domestic Airport ) | 3,000 $ /ឆ្នាំ | | 5ឆ្នាំ |
| 1.3 | ឧទ្ធម្ភាគចក្រដ្ឋាន ( Heliport ) | 2,400 $ /ឆ្នាំ | | 5ឆ្នាំ |
| 1.4 | ព្រលានឧទ្ធម្ភាគចក្រ ( Helipad ) | 2,000 $ /ឆ្នាំ | | 5ឆ្នាំ |
| II | **នាយកដ្ឋានសន្តិសុខអាកាសចរស៊ីវិល** | | | |
| 1 | បណ្តុះបណ្តាល និងចេញវិញ្ញាបនបត្រ | | | |
| 1.1 | បើកវគ្គបណ្តុះបណ្តាល និងចេញវិញ្ញាបនបត្រសន្តិសុខថ្នាក់បឋម | 50 $ /ម្នាក់ | 12ថ្ងៃ | 2ឆ្នាំ |
| 1.2 | ធ្វើតេស្ត និងបន្តវិញ្ញាបនបត្រសន្តិសុខថ្នាក់បឋម | 25 $ /ម្នាក់ | 5ថ្ងៃ | 2ឆ្នាំ |

| ល.រ | បរិយាយ | តម្លៃសេវា (ដុល្លារអាមេរិក) | រយៈពេលផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|
| 2 | ពិនិត្យកម្មវិធីសន្តិសុខ | | | |
| 2.1 | ពិនិត្យ និងផ្តល់ការយល់ព្រមលើកម្មវិធីសន្តិសុខអាកាសយានដ្ឋាន និងកម្មវិធីសន្តិសុខក្រុមហ៊ុនអាកាសចរណ៍ | 200$ /ក្រុមហ៊ុន | 2ខែ | 2ឆ្នាំ |
| 2.2 | ពិនិត្យឡើងវិញ និងបន្តសុពលភាពដល់កម្មវិធីសន្តិសុខអាកាសអាកាសយានដ្ឋាន និងក្រុមហ៊ុនអាកាសចរណ៍ | 100$ /ក្រុមហ៊ុន | 14ថ្ងៃ | 2ឆ្នាំ |
| III. | **នាយកដ្ឋានរដ្ឋបាល និងគ្រប់គ្រងធនធានមនុស្ស** | | | |
| 1 | ការធ្វើតេស្តលើភាពស្ទាត់ជំនាញភាសាអង់គ្លេស អាកាសចរស៊ីវិល | 50 $ /ម្នាក់ | 14ថ្ងៃ | - កម្រិត4 មានសុពលភាព3ឆ្នាំ<br>- កម្រិត5 មានសុពលភាព 5ឆ្នាំ |
| IV. | **នាយកដ្ឋានដឹកជញ្ជូនតាមផ្លូវអាកាស** | | | |
| 1 | ចេញលិខិតអនុញ្ញាត្តិសម្រាប់ប្រតិបត្តិការហោះហើរតាមជើងកាលរបស់ក្រុមហ៊ុនអាកាសចរណ៍ក្នុងស្រុក និងបរទេស | 200 $ /ក្រុមហ៊ុន | 7ថ្ងៃ មុនពេលចាប់ផ្តើមហោះហើរ | 6ខែ |
| 2 | ចេញលិខិតអនុញ្ញាត្តិសម្រាប់ប្រតិបត្តិហោះហើរជាលក្ខណៈ Charter/Extra Flight របស់ក្រុមហ៊ុនអាកាសចរណ៍ក្នុងស្រុក និងបរទេស | 200 $ / ម្តង | 2ថ្ងៃ មុនពេលចាប់ផ្តើមហោះហើរ | |
| 3 | ចេញលិខិតអនុញ្ញាត្តសម្រាប់ការផ្លាស់ប្តូរប្រភេទអាកាសយាន ឬផ្លាស់ប្តូរផ្លូវហោះហើររបស់ក្រុមហ៊ុនអាកាសចរណ៍ក្នុងស្រុក និងបរទេស | 200 $ / ម្តង | 2ថ្ងៃ មុនពេលចាប់ផ្តើមហោះហើរ | |
| 4 | ចេញលិខិតចាត់តាំងក្រុមហ៊ុនអាកាសចរណ៍ក្នុងស្រុកហោះហើរទៅកាន់បរទេស | 500 $ /ប្រទេស | 60ថ្ងៃ មុនពេលចាប់ផ្តើមហោះហើរ | |

| ល.រ | បរិយាយ | តម្លៃសេវា (ដុល្លារអាមេរិក) | រយៈពេលផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|
| 5 | រាល់ការចេញវិញ្ញាបនបត្រ ទំនិញគ្រោះថ្នាក់ជានាវាប៉ងរង គុណភាពសេវាកម្ម សម្រាប់បម្រើអោយក្រុមហ៊ុនអាកាសចរណ៍ក្នុងស្រុក និងបរទេស (តាមការស្នើសុំ) | 500 $ /វិញ្ញាបនបត្រ | 15ថ្ងៃ មុនពេលចាប់ផ្តើមហោះហើរ | 2ឆ្នាំ |
| V. | **នាយកដ្ឋានស្តង់ដា និងសុវត្ថិភាពហោះហើរ** | | | |
| 1 | ចេញវិញ្ញាបនបត្រប្រតិបត្តិការផ្លូវអាកាស (លើកដំបូង) (Air Operator Certificate Requirement-AOCR): | | | |
| 1.1 | អាកាសយានធុនស្រាល (Light Aircraft) ដែលមានទម្ងន់តិចជាង 5,700 Kg | 50,000 $ /ក្រុមហ៊ុន | 3ខែ | 1ឆ្នាំ |
| 1.2 | អាកាសយានធុនមធ្យម (Medium Aircraft) ដែលមានទម្ងន់ចាប់ពី 5,700Kg ទៅ 136T | 100,000 $ /ក្រុមហ៊ុន | 3ខែ | 1ឆ្នាំ |
| 1.3 | អាកាសយានធុនធ្ងន់ (Heavy Aircraft) ដែលមានទម្ងន់ចាប់ពី 136T ឡើងទៅ | 150,000 $ /ក្រុមហ៊ុន | 3ខែ | 1ឆ្នាំ |
| 2 | ចេញវិញ្ញាបនបត្រពន្យារសុពលភាពប្រតិបត្តិការផ្លូវអាកាស(Air Operator Certificate Requirement Renewal-AOCRR): | | | |
| 2.1 | អាកាសយានធុនស្រាល (Light Aircraft) ដែលមានទម្ងន់តិចជាង 5,700 Kg | 5,000 $ /ក្រុមហ៊ុន | 2ខែ | 1ឆ្នាំ |
| 2.2 | អាកាសយានធុនមធ្យម (Medium Aircraft) ដែលមានទម្ងន់ចាប់ពី 5,700Kg ទៅ 136T | 10,000 $ /ក្រុមហ៊ុន | 2ខែ | 1ឆ្នាំ |
| 2.3 | អាកាសយានធុនធ្ងន់ (Heavy Aircraft) ដែលមានទម្ងន់ចាប់ ពី 136T ឡើងទៅ | 15,000 $ /ក្រុមហ៊ុន | 2ខែ | 1ឆ្នាំ |
| 3 | ការប្រែប្រួល(បន្ថែម/បន្ថយយន្តហោះ)លក្ខខណ្ឌកិច្ចប្រតិបត្តិការហោះហើរអមវិញ្ញាបនបត្រប្រតិបត្តិការផ្លូវអាកាស: | | | |
| 3.1 | អាកាសយានធុនស្រាល (Light Aircraft) ដែលមានទម្ងន់តិចជាង 5,700 Kg | 1,000 $ /គ្រឿង | 2ខែ | អចិន្ត្រៃយ៍ |
| 3.2 | អាកាសយានធុនមធ្យម (Medium Aircraft) ដែលមានទម្ងន់ចាប់ពី 5,700 Kg ទៅ 136T | 2,000 $ /គ្រឿង | 2ខែ | អចិន្ត្រៃយ៍ |
| 3.3 | អាកាសយានធុនធ្ងន់ (Heavy Aircraft) ដែលមានទម្ងន់ចាប់ពី 136T ឡើងទៅ | 3,000 $ /គ្រឿង | 2ខែ | អចិន្ត្រៃយ៍ |

| ល.រ | បរិយាយ | តម្លៃសេវា (ដុល្លារអាមេរិក) | រយៈពេលផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|
| 4 | ចេញវិញ្ញាបនបត្រសាលាហ្វឹកហ្វឺនអាកាសចរស៊ីវិលៈ | | | |
| 4.1 | កម្រិត1 ( Aviation Training Organization-ATO Level 1 ) | 5,000 $ /ក្រុមហ៊ុន | 2ខែ | 1ឆ្នាំ |
| 4.2 | កម្រិត2 ( Aviation Training Organization -ATO Level 2 ) | 10,000 $ /ក្រុមហ៊ុន | 2ខែ | 1ឆ្នាំ |
| 4.3 | កម្រិត3( Aviation Training Organization -ATO Level 3 ) | 20,000 $ /ក្រុមហ៊ុន | 2ខែ | 1ឆ្នាំ |
| 5 | រាល់ឯកសារដែលអនុញ្ញាត្ត ការទទួលស្គាល់ និងលិខិតបញ្ជាក់ផ្សេងៗ | 0 ៛ | 7ថ្ងៃ - 30ថ្ងៃ | 1ឆ្នាំ |
| 6 | វិញ្ញាបនបត្រសិស្សអាកាសយានិក | 0 ៛ | 10 ថ្ងៃ | 2ឆ្នាំ |
| 7 | អាជ្ញាប័ណ្ណអាកាសយានិកឯកជន | 0 ៛ | 10 ថ្ងៃ | 2ឆ្នាំ |
| 8 | អាជ្ញាប័ណ្ណអាកាសយានិកពាណិជ្ជកម្ម | 0 ៛ | 10 ថ្ងៃ | 1ឆ្នាំ |
| 9 | អាជ្ញាប័ណ្ណអាកាសយានិកដឹកជញ្ជូនផ្លូវអាកាស | 0 ៛ | 10 ថ្ងៃ | 6ខែ |
| 10 | វិញ្ញាបនបត្របាហុនិកា | 0 ៛ | 10 ថ្ងៃ | 1ឆ្នាំ |
| VI. | **នាយកដ្ឋានលទ្ធភាពហោះហើរ** | | | |
| 1 | ចេញវិញ្ញាបនបត្រអាកាសយានធុនស្រាល ( ទម្ងន់ហោះឡើងសរុបតិចជាង 5,700 គក្រ ) សម្រាប់ៈ | | | |
| 1.1 | ចុះបញ្ជី | 500 $ | មិនតិចជាង 2ខែ | អចិន្ត្រៃយ៍ |
| 1.2 | ដកបញ្ជី | 100 $ | មិនតិចជាង 2ខែ | អចិន្ត្រៃយ៍ |
| 1.3 | លទ្ធភាពហោះហើរ | 1,000 $/ដង | មិនតិចជាង 2ខែ | 1ឆ្នាំ |
| 1.4 | បន្តលទ្ធភាពហោះហើរ | 700 $/ដង | មិនតិចជាង 2ខែ | 1ឆ្នាំ |
| 1.5 | លទ្ធភាពហោះហើរនាំចេញ | 1,000 $ /ដង | មិនតិចជាង 2ខែ | 1ឆ្នាំ |

| ល.រ | បរិយាយ | តម្លៃសេវា (ដុល្លារអាមេរិក) | រយៈពេលផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|
| 2 | ចេញវិញ្ញាបនបត្រអាកាសយានធុនធ្ងន់ ( ទម្ងន់ហោះឡើងសរុបចាប់ពី 5,700 គក្រ ) សម្រាប់: | | | |
| 2.1 | ចុះបញ្ជី | 100kg=7$ ទម្ងន់ហោះឡើងសរុប | មិនតិចជាង 2ខែ | អចិន្ត្រៃយ៍ |
| 2.2 | ដកបញ្ជី | 100kg=1$ ទម្ងន់ហោះឡើងសរុប | មិនតិចជាង 2ខែ | អចិន្ត្រៃយ៍ |
| 2.3 | លទ្ធភាពហោះហើរ | 100kg=12$ ទម្ងន់ហោះឡើងសរុប | មិនតិចជាង 2ខែ | 1ឆ្នាំ |
| 2.4 | បន្តលទ្ធភាពហោះហើរ | 100kg=10$ ទម្ងន់ហោះឡើងសរុប | មិនតិចជាង 2ខែ | 1ឆ្នាំ |
| 2.5 | លទ្ធភាពហោះហើរនាំចេញ | 100kg=12$ ទម្ងន់ហោះឡើងសរុប | មិនតិចជាង 2ខែ | 1ឆ្នាំ |
| 3 | អាជ្ញាប័ណ្ណវិទ្យុអាកាសយាន | 150 $/ដង | មិនតិចជាង 2ខែ | 2ឆ្នាំ |
| 4 | បន្តអាជ្ញាប័ណ្ណវិទ្យុអាកាសយាន | 100 $/ដង | មិនតិចជាង 2ខែ | 2ឆ្នាំ |
| 5 | វិញ្ញាបនបត្រសំលេង | 150 $ | មិនតិចជាង 2ខែ | អចិន្ត្រៃយ៍ |
| 6 | អង្គភាពជួសជុលថែរក្សាបច្ចេកទេសអាកាសយានធុនស្រាល ( ទម្ងន់ហោះឡើងសរុបតិចជាង 5,700 គក្រ ) | | | |
| 6.1 | ឯកភាព | 1,200 $/ដង | មិនតិចជាង 3ខែ | 1ឆ្នាំ |
| 6.2 | បន្តឯកភាព | 1,000 $/ដង | មិនតិចជាង 3ខែ | 1ឆ្នាំ |

| ល.រ | បរិយាយ | តម្លៃសេវា (ដុល្លារអាមេរិក) | រយៈពេលផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|
| 7 | អង្គភាពជួសជុលថែរក្សាបច្ចេកទេសអាកាសយានធុនធំ ( ទម្ងន់ហោះឡើងសរុបចាប់ពី 5,700 គក្រ ) | | | |
| 7.1 | ឯកភាព | 2,400 $/ដង | មិនតិចជាង 3ខែ | 1ឆ្នាំ |
| 7.2 | បន្តឯកភាព | 2,000 $/ដង | មិនតិចជាង 3ខែ | 1ឆ្នាំ |
| 8 | អាជ្ញាប័ណ្ណស្ថានីយប្រេងអាកាសយាន | 1,800 $/ដង | មិនតិចជាង 3ខែ | 1ឆ្នាំ |
| 9 | បន្តអាជ្ញាប័ណ្ណស្ថានីយប្រេងអាកាសយាន | 1,400 $/ដង | មិនតិចជាង 3ខែ | 1ឆ្នាំ |
| 10 | វិញ្ញាបនបត្រ ឬអាជ្ញាប័ណ្ណ ទុតិយតា | 100 $/ដង | 14ថ្ងៃ | ផ្អែកលើឯកសារដើម |
| 11 | ផ្តល់ការអនុញ្ញាត ឬការកែប្រែនូវឯកសារបច្ចេកទេសផ្សេងៗ | 100 $/ដង | 14ថ្ងៃ | ផ្អែកលើឯកសារដើម |
| VI. | **នាយកដ្ឋានគស្តុភារ និងហិរញ្ញវត្ថុ** | | | |
| 1 | កម្រៃសិទ្ធិហោះហើរតែម្ខាង ( Traffic Right Charge-Royalty ) នៅអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ, ខេត្តសៀមរាប និងខេត្តព្រះសីហនុ | | | |
| 1.1 | ទម្ងន់យន្តហោះចាប់ពី 10តោន ចុះ | 250 $ / ជើងហោះហើរ | | |
| 1.2 | ទម្ងន់យន្តហោះលើសពី 10តោន ដល់ 25តោន | 500 $ / ជើងហោះហើរ | | |
| 1.3 | ទម្ងន់យន្តហោះលើសពី 25តោន ដល់ 70តោន | 750 $ / ជើងហោះហើរ | | |
| 1.4 | ទម្ងន់យន្តហោះលើសពី 70តោន ឡើងទៅ | 1,000 $ / ជើងហោះហើរ | | |

| ល.រ | បរិយាយ | តម្លៃសេវា (ដុល្លារអាមេរិក) | រយៈពេលផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|
| 2 | សេវាហោះហើរឆ្លងកាត់ ( Over Flight Service Charge ) | | | |
| 2.1 | ទម្ងន់យន្តហោះចាប់ពី 0តោន ដល់ 03តោន | 66 $ / ជើងហោះហើរ | | |
| 2.2 | ទម្ងន់យន្តហោះចាប់ពី 04តោន ដល់ 10តោន | 108 $ / ជើងហោះហើរ | | |
| 2.3 | ទម្ងន់យន្តហោះចាប់ពី 11តោន ដល់ 25តោន | 216 $ / ជើងហោះហើរ | | |
| 2.4 | ទម្ងន់យន្តហោះចាប់ពី 26តោន ដល់ 50តោន | 324 $ / ជើងហោះហើរ | | |
| 2.5 | ទម្ងន់យន្តហោះចាប់ពី 51តោន ដល់ 100តោន | 412 $ / ជើងហោះហើរ | | |
| 2.6 | ទម្ងន់យន្តហោះចាប់ពី 101តោន ដល់ 200តោន | 454 $ / ជើងហោះហើរ | | |
| 2.7 | ទម្ងន់យន្តហោះចាប់ពី 201តោន ដល់ 300តោន | 486 $ / ជើងហោះហើរ | | |
| 2.8 | ទម្ងន់យន្តហោះលើសពី 300តោន | 515 $ / ជើងហោះហើរ | | |

| ល.រ | បរិយាយ | តម្លៃសេវា (ដុល្លារអាមេរិក) | រយៈពេលផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|
| 3 | សេវានាំផ្លូវចុះចត និងហោះឡើង ( Landing & Take Off Service Charge ) | | | |
| 3.1 | ទម្ងន់យន្តហោះចាប់ពី 0តោន ដល់ 03តោន | 116 $ / ជើងហោះហើរ | | |
| 3.2 | ទម្ងន់យន្តហោះចាប់ពី 04តោន ដល់ 10តោន | 193 $ / ជើងហោះហើរ | | |
| 3.3 | ទម្ងន់យន្តហោះចាប់ពី 11តោន ដល់ 25តោន | 386 $ / ជើងហោះហើរ | | |
| 3.4 | ទម្ងន់យន្តហោះចាប់ពី 26តោន ដល់ 50តោន | 580 $ / ជើងហោះហើរ | | |
| 3.5 | ទម្ងន់យន្តហោះចាប់ពី 51តោន ដល់ 100តោន | 734 $ / ជើងហោះហើរ | | |
| 3.6 | ទម្ងន់យន្តហោះចាប់ពី 101តោន ដល់ 200តោន | 773 $ / ជើងហោះហើរ | | |
| 3.7 | ទម្ងន់យន្តហោះចាប់ពី 201តោន ដល់ 300តោន | 812 $ / ជើងហោះហើរ | | |
| 3.8 | ទម្ងន់យន្តហោះលើសពី 300តោន | 850 $ / ជើងហោះហើរ | | |

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

MINISTRY OF ECONOMY AND FINANCE

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ១៣៥ សហវ.ប្រក

រាជធានីភ្នំពេញ, ថ្ងៃទី ២៩ ខែ មករា ឆ្នាំ ២០១៣

# ប្រកាសរួម

## ស្តីពី

## ការផ្តល់ទង់លើកទឹកចិត្តជូន

## រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## រដ្ឋលេខាធិការ រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០០ និងអនុក្រឹត្យពាក់ព័ន្ធ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ១៨ អនក្រ.បក ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St,92, Sangkat Wat Phnom , khan Daun Penh, Phnom Penh, CAMBODIA.
www.mef.gov.kh
ទូរសព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798
mef_adm@yahoo.com

- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញបទបញ្ជាលេខ ០៤ បប. ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០០៦ របស់រាជរដ្ឋាភិបាល ស្តីពីការពង្រឹងការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ
- យោងប្រកាសរួមលេខ ១៣៤ សហវ.ប្រក ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៣ ស្តីពីការផ្តល់សេវាសាធារណៈរបស់រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល

## សម្រេច

**ប្រការ ១** :

ត្រូវបានផ្តល់ប្រាក់រង្វាន់លើកទឹកចិត្ត ជូនរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សម្រាប់ឧបត្ថម្ភជូនមន្ត្រីដែលបំពេញភារកិច្ចផ្ទាល់ និងមន្ត្រីផ្សេងៗទៀត លើការបម្រើសេវាសាធារណៈ ព្រមទាំងសម្រាប់ពង្រឹងយន្តការប្រមូលចំណូល។

**ប្រការ ២** :

អនុញ្ញាតឱ្យរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល កាត់ទុកជាមុននូវចំណែកប្រាក់រង្វាន់ ដោយដកយកពីប្រាក់ចំណូលដែលប្រមូលបានពីការផ្តល់សេវាសាធារណៈ ដូចបានកំណត់ដោយប្រកាសរួមលេខ ១៣៤ សហវ.ប្រក ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៣ ស្តីពីការផ្តល់សេវាសាធារណៈរបស់រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល។ ការកាត់ទុកជាមុននូវចំណែកប្រាក់រង្វាន់នេះ ត្រូវបានចាត់ទុកថា ថវិកាជាតិបានបើកផ្តល់ជាប្រាក់បុរេប្រទានជូនរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល សម្រាប់ការចំណាយឧបត្ថម្ភជូនមន្ត្រី និងពង្រឹងយន្តការប្រមូលចំណូលដែលបានកំណត់នៅក្នុងប្រការ១ នៃប្រកាសរួមនេះ។ ប្រាក់រង្វាន់ដែលអនុញ្ញាតឱ្យកាត់ទុកជាមុននេះ រួមមានចំណែកប្រាក់រង្វាន់របស់រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល និងចំណែកប្រាក់រង្វាន់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**ប្រការ ៣** :

ការផ្តល់ប្រាក់រង្វាន់ជូនរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវបានកំណត់ជាសមាមាត្រភាគរយធៀបទៅនឹងប្រាក់ចំណូលប្រមូលបាន និងត្រូវបានបែងចែក ដូចខាងក្រោម ៖

- បង់ចូលថវិកាជាតិ តាមចំណែកដែលកំណត់ក្នុងតារាងឧបសម្ព័ន្ធ
- ជូនរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល តាមចំណែកដែលកំណត់ក្នុងតារាងឧបសម្ព័ន្ធ
- ជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមចំណែកដែលកំណត់ក្នុងតារាងឧបសម្ព័ន្ធ ៚

**ប្រការ ៤** :

រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល ត្រូវគ្រោងចំណូល និងចំណាយដែលជាកម្មវត្ថុសម្រាប់ការផ្តល់ប្រាក់រង្វាន់លើកទឹកចិត្ត នៅក្នុងគម្រោងចំណូល និងចំណាយនៃថវិកាប្រចាំឆ្នាំរបស់ខ្លួន។ រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល ត្រូវគ្រោងឥណទានប្រាក់រង្វាន់ ដោយគិតបញ្ចូលរួមទាំងឥណទានសម្រាប់ការចំណាយលើប្រាក់រង្វាន់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

រាល់ប្រតិបត្តិការនៃចំណូល និងចំណាយទាំងនេះ ត្រូវកត់ត្រាឆ្លុះបញ្ចាំងក្នុងថវិកាជាតិ ដូចប្រតិបត្តិការនៃចំណូល និងចំណាយដទៃទៀតរបស់រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល។ ឥណទានដែលបានគ្រោងសម្រាប់ការចំណាយលើប្រាក់រង្វាន់នេះ ជាកម្មវត្ថុនៃការធ្វើអាណត្តិបើកប្រាក់ ដើម្បីទូទាត់ជាមួយចំនួនទឹកប្រាក់ដែលចាត់ទុកថាបានបុរេប្រទានពីថវិកាជាតិ(ប្រាក់ចំណូលដែលបានកាត់ទុកជាមុន)។

ការកត់ត្រាចំណូល និងចំណាយក្នុងកិច្ចប្រតិបត្តិការថវិកាជាតិ លើការផ្តល់ប្រាក់រង្វាន់លើកទឹកចិត្ត ត្រូវអនុវត្តតាមនីតិវិធីទូទាត់ប្រាក់បុរេប្រទាន ដូចខាងក្រោម ៖

ក. ផ្នែកចំណូលៈត្រូវធ្វើសលាកប័ត្រចំណូលថវិកាជាតិ នូវចំនួនទឹកប្រាក់ដែលបានបុរេប្រទាន ៖ ត្រូវរៀបចំ និងបញ្ជូនសលាកប័ត្រចំណូលថវិកាជាតិ មកនាយកដ្ឋានចំណូលមិនមែនសារពើពន្ធ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយភ្ជាប់មកជាមួយនូវរបាយការណ៍ស្ថានភាព ស្តីពីការអនុវត្តចំណូល និងតារាង ស្តីពីការគណនាប្រាក់រង្វាន់ ព្រមទាំងរបាយការណ៍ ស្តីពីការបែងចែកប្រាក់រង្វាន់ដែលបានបើកផ្តល់កន្លងមក។ នាយកដ្ឋានចំណូលមិនមែនសារពើពន្ធ ត្រូវចេញលិខិតពិនិត្យបញ្ជាក់លើចំនួនទឹកប្រាក់ដែលបានចុះក្នុងសលាកប័ត្រ។

ខ. ផ្នែកចំណាយៈ ត្រូវធ្វើអាណត្តិបើកប្រាក់ ដោយចុះចំនួនទឹកប្រាក់ស្មើនឹងចំនួនទឹកប្រាក់បុរេប្រទានដែលបានចុះនៅក្នុងសលាកប័ត្រចំណូលថវិកាជាតិ។

**ប្រការ ៥** :

ក្រោយពីបានបំពេញនីតិវិធី ដែលមានចែងក្នុងប្រការ ៤ ខាងលើ ការបើកផ្តល់ប្រាក់រង្វាន់លើកទឹកចិត្តត្រូវអនុវត្ត ដូចខាងក្រោម ៖

ក. ការបើកផ្តល់ប្រាក់រង្វាន់ជូនមន្ត្រីរាជការនៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល ត្រូវអនុលោមតាមការសម្រេចរបស់រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល ដោយឈរលើគោលការណ៍សមធម៌ និងផ្អែកតាមគុណសម្បត្តិការងារ។

ខ. ការបើកផ្តល់ប្រាក់រង្វាន់ជូនមន្ត្រីរាជការនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវអនុលោមតាមការសម្រេចរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយឈរលើគោលការណ៍សមធម៌ និងផ្អែកតាមគុណសម្បត្តិការងារ។

**ប្រការ ៦** :

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសរួមនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ៧** :

អគ្គលេខាធិការ នាយកខុទ្ទកាល័យ អគ្គនាយក ប្រធាននាយកដ្ឋាន និងប្រធានអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រោមឱវាទរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល ត្រូវទទួលបន្ទុកអនុវត្តប្រកាសរួមនេះ ឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**គាត ឈន់**

**រដ្ឋលេខាធិការ**
**រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល**

**ម៉ៅ ហាវណ្ណាល់**

ចម្លងជូនៈ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី
- អាជ្ញាធរសវនកម្មជាតិ
- អង្គភាពប្រឆាំងអំពើពុករលួយ
- គ្រប់រដ្ឋបាលរាជធានី ខេត្ត

«ដើម្បីជូនជ្រាប»
- ដូចប្រការ ៧ «ដើម្បីអនុវត្ត»
- ឯកសារ - កាលប្បវត្តិ

# តារាងឧបសម្ព័ន្ធ

## ភ្ជាប់នឹងប្រកាសរួមលេខ ១៣៥ សហវ.ប្រក ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៣

## ស្តីពីការផ្តល់ទ្រាន់លើកទឹកចិត្ត ជូនរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល(រ.ល.អ.ស) និង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ(ក. សហវ)

| ល.រ | បរិយាយ | អត្រាបែងចែក | | |
|---|---|---|---|---|
| | | ថវិកាជាតិ | រ.ល.អ.ស | ក. សហវ |
| I | **នាយកដ្ឋានស្តង់ដា និងសុវត្ថិភាពអាកាសយានដ្ឋាន** | | | |
| 1 | ចេញវិញ្ញាបនបត្រប្រកបអាជីវកម្មអាកាសយានដ្ឋាន ( Airport Certificate ) សម្រាប់: | | | |
| 1.1 | អាកាសយានដ្ឋានអន្តរជាតិ ( International Airport ) | 70% | 29% | 1% |
| 1.2 | អាកាសយានដ្ឋានមូលដ្ឋាន ( Domestic Airport ) | 70% | 29% | 1% |
| 1.3 | ឧទ្ធម្ភាគចក្រដ្ឋាន ( Heliport ) | 70% | 29% | 1% |
| 1.4 | ព្រលានឧទ្ធម្ភាគចក្រ ( Helipad ) | 70% | 29% | 1% |
| II | **នាយកដ្ឋានសន្តិសុខអាកាសចរស៊ីវិល** | | | |
| 1 | បណ្តុះបណ្តាល និងចេញវិញ្ញាបនបត្រ | | | |
| 1.1 | បើកវគ្គបណ្តុះបណ្តាល និងចេញវិញ្ញាបនបត្រសន្តិសុខថ្នាក់បឋម | 10% | 89% | 1% |
| 1.2 | ធ្វើតេស្ត និងបន្តវិញ្ញាបនបត្រសន្តិសុខថ្នាក់បឋម | 10% | 89% | 1% |
| 2 | ពិនិត្យកម្មវិធីសន្តិសុខ | | | |
| 2.1 | ពិនិត្យ និងផ្តល់ការយល់ព្រមលើកម្មវិធីសន្តិសុខអាកាសយានដ្ឋាន និងកម្មវិធីសន្តិសុខក្រុមហ៊ុនអាកាសចរណ៍ | 50% | 49% | 1% |
| 2.2 | ពិនិត្យឡើងវិញ និងបន្តសុពលភាពដល់កម្មវិធីសន្តិសុខអាកាសយានដ្ឋាន និងក្រុមហ៊ុនអាកាសចរណ៍ | 50% | 49% | 1% |

| ល.រ | បរិយាយ | អត្រាបែងចែក | | |
|---|---|---|---|---|
| | | ថវិកាជាតិ | រ.ល.អ.ស | ក. សហវ |
| III. | **នាយកដ្ឋានរដ្ឋបាល និងគ្រប់គ្រងធនធានមនុស្ស** | | | |
| 1 | ការធ្វើតេស្តលើភាពស្ទាត់ជំនាញភាសាអង់គ្លេស អាកាសចរស៊ីវិល | 10% | 89% | 1% |
| IV. | **នាយកដ្ឋានដឹកជញ្ជូនតាមផ្លូវអាកាស** | | | |
| 1 | ចេញលិខិតអនុញ្ញាត្តិសម្រាប់ប្រតិបត្តិការហោះហើរតាមរដូវកាលរបស់ក្រុមហ៊ុនអាកាសចរណ៍ក្នុងស្រុក និងបរទេស | 50% | 49% | 1% |
| 2 | ចេញលិខិតអនុញ្ញាត្តិសម្រាប់ប្រតិបត្តិហោះហើរជាលក្ខណៈ Charter/Extra Flight របស់ក្រុមហ៊ុនអាកាសចរណ៍ក្នុងស្រុក និងបរទេស | 50% | 49% | 1% |
| 3 | ចេញលិខិតអនុញ្ញាត្តសម្រាប់ការផ្លាស់ប្តូរប្រភេទអាកាសយាន ឬផ្លាស់ប្តូរផ្លូវហោះហើររបស់ក្រុមហ៊ុនអាកាសចរណ៍ក្នុងស្រុក និងបរទេស | 50% | 49% | 1% |
| 4 | ចេញលិខិតចាត់តាំងក្រុមហ៊ុនអាកាសចរណ៍ក្នុងស្រុកហោះហើរទៅកាន់បរទេស | 50% | 49% | 1% |
| 5 | រាល់ការចេញវិញ្ញាបនបត្រ ទំនិញគ្រោះថ្នាក់ធានារ៉ាប់រង គុណភាពសេវាកម្ម សម្រាប់ប្រើឱ្យក្រុមហ៊ុនអាកាសចរណ៍ក្នុងស្រុក និងបរទេស (តាមការស្នើសុំ) | 50% | 49% | 1% |
| V. | **នាយកដ្ឋានស្តង់ដា និងសុវត្ថិភាពហោះហើរ** | | | |
| 1 | ចេញវិញ្ញាបនបត្រប្រតិបត្តិការផ្លូវអាកាស (លើកដំបូង) (Air Operator Certificate Requirement-AOCR): | | | |
| 1.1 | អាកាសយានធុនស្រាល (Light Aircraft) ដែលមានទម្ងន់តិចជាង 5,700 Kg | 70% | 29% | 1% |
| 1.2 | អាកាសយានធុនមធ្យម (Medium Aircraft) ដែលមានទម្ងន់ចាប់ពី 5,700Kg ទៅ 136T | 70% | 29% | 1% |
| 1.3 | អាកាសយានធុនធ្ងន់ (Heavy Aircraft) ដែលមានទម្ងន់ចាប់ពី 136T ឡើងទៅ | 70% | 29% | 1% |

| ល.រ | បរិយាយ | អត្រាបែងចែក | | |
|---|---|---|---|---|
| | | ថវិកាជាតិ | រ.ល.អ.ស | ក. សហវ |
| 2 | ចេញវិញ្ញាបនបត្រពន្យារសុពលភាពប្រតិបត្តិការផ្លូវអាកាស(Air Operator Certificate Requirement Renewal-AOCRR): | | | |
| 2.1 | អាកាសយានធុនស្រាល (Light Aircraft) ដែលមានទម្ងន់តិចជាង 5,700 Kg | 70% | 29% | 1% |
| 2.2 | អាកាសយានធុនមធ្យម (Medium Aircraft) ដែលមានទម្ងន់ចាប់ពី 5,700Kg ទៅ 136T | 70% | 29% | 1% |
| 2.3 | អាកាសយានធុនធ្ងន់ (Heavy Aircraft) ដែលមានទម្ងន់ចាប់ ពី 136T ឡើងទៅ | 70% | 29% | 1% |
| 3 | ការប្រែប្រួល(បន្ថែម/បន្ថយយន្តហោះ)លក្ខខណ្ឌកិច្ចប្រតិបត្តិការហោះហើរអមវិញ្ញាបនបត្រប្រតិបត្តិការផ្លូវអាកាសៈ | | | |
| 3.1 | អាកាសយានធុនស្រាល (Light Aircraft) ដែលមានទម្ងន់តិចជាង 5,700 Kg | 50% | 49% | 1% |
| 3.2 | អាកាសយានធុនមធ្យម (Medium Aircraft) ដែលមានទម្ងន់ចាប់ពី 5,700 Kg ទៅ 136T | 50% | 49% | 1% |
| 3.3 | អាកាសយានធុនធ្ងន់ (Heavy Aircraft) ដែលមានទម្ងន់ចាប់ពី 136T ឡើងទៅ | 50% | 49% | 1% |
| 4 | ចេញវិញ្ញាបនបត្រសាលាហ្វឹកហ្វឺនអាកាសចរស៊ីវិលៈ | | | |
| 4.1 | កម្រិត1 (Aviation Training Organization-ATO Level 1) | 50% | 49% | 1% |
| 4.2 | កម្រិត2 (Aviation Training Organization -ATO Level 2) | 50% | 49% | 1% |
| 4.3 | កម្រិត3(Aviation Training Organization -ATO Level 3) | 50% | 49% | 1% |
| 5 | រាល់ឯកសារដែលអនុញ្ញាត្ត ការទទួលស្គាល់ និងលិខិតបញ្ជាក់ផ្សេងៗ | 0% | 0% | 0% |
| 6 | វិញ្ញាបនបត្រសិស្សអាកាសយានិក | 0% | 0% | 0% |
| 7 | អាជ្ញាប័ណ្ណអាកាសយានិកឯកជន | 0% | 0% | 0% |
| 8 | អាជ្ញាប័ណ្ណអាកាសយានិកពាណិជ្ជកម្ម | 0% | 0% | 0% |
| 9 | អាជ្ញាប័ណ្ណអាកាសយានិកដឹកជញ្ជូនផ្លូវអាកាស | 0% | 0% | 0% |
| 10 | វិញ្ញាបនបត្របាហុនិកា | 0% | 0% | 0% |

| ល.រ | បរិយាយ | អត្រាបែងចែក | | |
|---|---|---|---|---|
| | | ថវិកាជាតិ | រ.ល.អ.ស | ក. សហវ |
| VI. | **នាយកដ្ឋានលទ្ធភាពហោះហើរ** | | | |
| 1 | ចេញវិញ្ញាបនបត្រអាកាសយានធុនស្រាល (ទម្ងន់ហោះឡើងសរុបតិចជាង 5,700 គក្រ) សម្រាប់: | | | |
| 1.1 | ចុះបញ្ជី | 50% | 49% | 1% |
| 1.2 | ដកបញ្ជី | 50% | 49% | 1% |
| 1.3 | លទ្ធភាពហោះហើរ | 50% | 49% | 1% |
| 1.4 | បន្តលទ្ធភាពហោះហើរ | 50% | 49% | 1% |
| 1.5 | លទ្ធភាពហោះហើរនាំចេញ | 50% | 49% | 1% |
| 2 | ចេញវិញ្ញាបនបត្រអាកាសយានធុនធ្ងន់ (ទម្ងន់ហោះឡើងសរុបចាប់ពី 5,700 គក្រ) សម្រាប់: | | | |
| 2.1 | ចុះបញ្ជី | 50% | 49% | 1% |
| 2.2 | ដកបញ្ជី | 50% | 49% | 1% |
| 2.3 | លទ្ធភាពហោះហើរ | 50% | 49% | 1% |
| 2.4 | បន្តលទ្ធភាពហោះហើរ | 50% | 49% | 1% |
| 2.5 | លទ្ធភាពហោះហើរនាំចេញ | 50% | 49% | 1% |
| 3 | អាជ្ញាប័ណ្ណវិទ្យុអាកាសយាន | 50% | 49% | 1% |
| 4 | បន្តអាជ្ញាប័ណ្ណវិទ្យុអាកាសយាន | 50% | 49% | 1% |
| 5 | វិញ្ញាបនបត្រសំលេង | 50% | 49% | 1% |
| 6 | អង្គភាពជួសជុលថែរក្សាបច្ចេកទេសអាកាសយានធុនស្រាល (ទម្ងន់ហោះឡើងសរុបតិចជាង 5,700 គក្រ) | | | |
| 6.1 | ឯកភាព | 50% | 49% | 1% |
| 6.2 | បន្តឯកភាព | 50% | 49% | 1% |

| ល.រ | បរិយាយ | អត្រាបែងចែក | | |
|---|---|---|---|---|
| | | ថវិកាជាតិ | រ.ល.អ.ស | ក. សហវ |
| 7 | អង្គភាពជួសជុលថែរក្សាបច្ចេកទេសអាកាសយានធុនធ្ងន់ ( ទម្ងន់ហោះឡើងសរុបចាប់ពី 5,700 គក្រ ) | | | |
| 7.1 | ឯកភាព | 50% | 49% | 1% |
| 7.2 | បន្តឯកភាព | 50% | 49% | 1% |
| 8 | អាជ្ញាប័ណ្ណស្ថានីយប្រេងអាកាសយាន | 50% | 49% | 1% |
| 9 | បន្តអាជ្ញាប័ណ្ណស្ថានីយប្រេងអាកាសយាន | 50% | 49% | 1% |
| 10 | វិញ្ញាបនប័ត្រ ឬអាជ្ញាប័ណ្ណ ទុតិយតា | 50% | 49% | 1% |
| 11 | ផ្តល់ការអនុញ្ញាត ឬការកែប្រែនូវឯកសារបច្ចេកទេសផ្សេងៗ | 50% | 49% | 1% |
| VI. | **នាយកដ្ឋានគស្តុគារ និងហិរញ្ញវត្ថុ** | | | |
| 1 | កម្រៃសិទ្ធិហោះហើរតែម្ខាង ( Traffic Right Charge-Royalty ) នៅអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ, ខេត្តសៀមរាប និងខេត្តព្រះសីហនុ | | | |
| 1.1 | ទម្ងន់យន្តហោះចាប់ពី 10តោន ចុះ | 80% | 19% | 1% |
| 1.2 | ទម្ងន់យន្តហោះលើសពី 10តោន ដល់ 25តោន | 80% | 19% | 1% |
| 1.3 | ទម្ងន់យន្តហោះលើសពី 25តោន ដល់ 70តោន | 80% | 19% | 1% |
| 1.4 | ទម្ងន់យន្តហោះលើសពី 70តោន ឡើងទៅ | 80% | 19% | 1% |
| 2 | សេវាហោះហើរឆ្លងកាត់( Over Flight Service Charge ) | | | |
| 2.1 | ទម្ងន់យន្តហោះចាប់ពី 0តោន ដល់ 03តោន | 80% | 19% | 1% |
| 2.2 | ទម្ងន់យន្តហោះចាប់ពី 04តោន ដល់ 10តោន | 80% | 19% | 1% |
| 2.3 | ទម្ងន់យន្តហោះចាប់ពី 11តោន ដល់ 25តោន | 80% | 19% | 1% |
| 2.4 | ទម្ងន់យន្តហោះចាប់ពី 26តោន ដល់ 50តោន | 80% | 19% | 1% |

| ល.រ | បរិយាយ | អត្រាបែងចែក | | |
|---|---|---|---|---|
| | | ថវិកាជាតិ | រ.ល.អ.ស | ក. សហវ |
| 2.5 | ទម្ងន់យន្តហោះចាប់ពី 51តោន ដល់ 100តោន | 80% | 19% | 1% |
| 2.6 | ទម្ងន់យន្តហោះចាប់ពី 101តោន ដល់ 200តោន | 80% | 19% | 1% |
| 2.7 | ទម្ងន់យន្តហោះចាប់ពី 201តោន ដល់ 300តោន | 80% | 19% | 1% |
| 2.8 | ទម្ងន់យន្តហោះលើសពី 300តោន | 80% | 19% | 1% |
| 3 | សេវានាំផ្លូវចុះចត និងហោះឡើង ( Landing & Take Off Service Charge ) | | | |
| 3.1 | ទម្ងន់យន្តហោះចាប់ពី 0តោន ដល់ 03តោន | 80% | 19% | 1% |
| 3.2 | ទម្ងន់យន្តហោះចាប់ពី 04តោន ដល់ 10តោន | 80% | 19% | 1% |
| 3.3 | ទម្ងន់យន្តហោះចាប់ពី 11តោន ដល់ 25តោន | 80% | 19% | 1% |
| 3.4 | ទម្ងន់យន្តហោះចាប់ពី 26តោន ដល់ 50តោន | 80% | 19% | 1% |
| 3.5 | ទម្ងន់យន្តហោះចាប់ពី 51តោន ដល់ 100តោន | 80% | 19% | 1% |
| 3.6 | ទម្ងន់យន្តហោះចាប់ពី 101តោន ដល់ 200តោន | 80% | 19% | 1% |
| 3.7 | ទម្ងន់យន្តហោះចាប់ពី 201តោន ដល់ 300តោន | 80% | 19% | 1% |
| 3.8 | ទម្ងន់យន្តហោះលើសពី 300តោន | 80% | 19% | 1% |